## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្ត អភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្ម ២០១៦-២០២០

វិច្ឆិកា ២០១៥

ឧបត្ថម្ភការរៀបចំគោលនយោបាយដោយៈ

ឧបត្ថម្ភការបោះពុម្ពដោយៈ

USAID
ជំនួយពីពលរដ្ឋអាមេរិក

Save the Children

Disclaimer：

The information and views set out in this publication are those of the author(s) and do not necessarily reflect the official opinion of the European Union. Neither the European Union institutions and bodies nor any person acting on their behalf may be held responsible for the use which may be made of the information contained therein.

Printing of this policy is made possible by the generous support of the American people through the United States Agency for International Development (USAID) under Cooperative Agreement No. AID-442-A-14-00006. The contents do not necessary reflect the views of USAID or the United States Government.

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ អភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្ម ២០១៦-២០២០

វិច្ឆិកា ២០១៥

# អារម្ភកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកថា ការអភិវឌ្ឍ និងការការពារកុមារ គឺជាបញ្ហាគន្លឹះមួយសម្រាប់ការអភិវឌ្ឍប្រទេសនាពេលអនាគត។ ក្រោមការដឹកនាំដ៏ខ្ពស់ខ្ពស់ និងភ្លឺស្វាងរបស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញយ៉ាងច្បាស់លាស់តាមរយៈគោលនយោបាយគាំពារ និងអភិវឌ្ឍន៍កុមារតូច ផែនការជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០០៣-២០១៥ និងផែនការជាតិសម្រាប់ការអភិវឌ្ឍកុមារ ឆ្នាំ២០១៥-២០១៨។ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ សម្រាប់កំណើនការងារ សមភាព និងប្រសិទ្ធភាពបានផ្តល់នូវក្របខ័ណ្ឌនៃការលើកកម្ពស់សុខមាលភាព និងសិទ្ធិកុមារដូចមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្តេជ្ញាយ៉ាងមុតមាំ ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអភិក្រមជាតិទាំងនេះ និងបានបង្កើតនូវក្របខ័ណ្ឌយុទ្ធសាស្រ្តរបស់ក្រសួង ដូចដែលមាននៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម(២០១៤-២០១៨)។ ទិសដៅជាយុទ្ធសាស្រ្តទាំងនេះ គឺជាការលើកកម្ពស់ដល់ការគាំពារ និងការអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ជាពិសេសដល់ក្រុមកុមារដែលងាយរងគ្រោះក្នុងគ្រួសារកសិករក្រីក្រ ដែលស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារនៅក្នុងវិស័យកសិកម្ម ឆ្នាំ ២០១៦-២០២០ គឺជាការបោះជំហានយ៉ាងសំខាន់មួយទៅកាន់ការសម្រេចបាននូវគោលដៅខាងលើ។ គោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ បានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយនឹងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗទៀត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្តល់យោបល់ និងកែលម្អនូវគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ។ ទន្ទឹមគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារយេនឌ័រនិងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធនានាដែលបានចូលរួមយ៉ាងសកម្ម និងមានការប្តេជ្ញាខ្ពស់ក្នុងដំណើរការនៃការចងក្រងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ។

ទាំងនេះ គឺជាការរួមចំណែកជាយុទ្ធសាស្រ្តយ៉ាងពេញលេញ និងទូលំទូលាយក្នុងការដោះស្រាយបញ្ហាប្រឈមដល់ការលើកកម្ពស់ជីវិតរស់នៅរបស់កុមារ និងយុវជនក្នុងវិស័យកសិកម្មនៅកម្ពុជា។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមអំពាវនាវដល់អង្គភាពក្រោមឱវាទក្រសួងគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធទាំងអស់ ចូលរួមយ៉ាងពេញទំហឹង និងសហការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការអនុវត្តយ៉ាងពេញលេញ និងមានប្រសិទ្ធភាពនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍និងការពារកុមារក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០នេះ

នឹងក្លាយជាជំហានដ៏សំខាន់មួយឈានទៅសម្រេចបាននូវផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់កុមារ និងយុវជន ក្នុងវិស័យកសិកម្ម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ឹក រ៉ាប៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
គណៈកម្មាធិការជាតិ
គាំពារនិងអភិវឌ្ឍកុមារតូច
លេខ....០៤០.....គ.ជ.គ.ក.[illegible]

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងការចាំបាច់របស់គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីជាយន្តការសម្របសម្រួលទំនាក់ទំនងការងាររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច។

**ប្រការ ២.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវ **ម៉ុម ថានី** | សមាជិកនៃគ.ជ.គ.ក. | ប្រធាន |
| ២. លោកស្រី **ភាំង ឃីម** | អនុប្រធានរដ្ឋបាលជលផល | អនុប្រធាន |
| ៣. លោកស្រី **គង់ សុធីរ៉ា** | ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. លោកស្រី **សាន ស៊ីឡេន** | អនុប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៥. លោកស្រី **មាស សុទ្ធាវី** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ | សមាជិក |
| ៦. លោកស្រី **អ៊ុក សាវិន** | អនុប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល | សមាជិក |
| ៧. កញ្ញា **ខឹម សុបញ្ញា** | អនុប្រធាននាយកដ្ឋាន នៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ៨. លោកស្រី **ទុយ សុខខេន** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៩. លោកស្រី **សុខ ជារដ្ឋា** | អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ១០. តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត | | សមាជិក |
| ១១. តំណាងដៃគូអភិវឌ្ឍ | | សមាជិក |

**ប្រការ ៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចក្នុងវិស័យយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការនិងសម្របសម្រួលការងារបច្ចេកទេសកុមារតូចក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈ កម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
- ជំរុញការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លើកសំណើកែលម្អគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចក្នុងវិស័យផែនការតាមរយៈអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

- សហការជាមួយមន្ទីរជំនាញតាមវិស័យនៅថ្នាក់រាជធានី ខេត្ត ការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងារគាំពារនិងអភិវឌ្ឍកុមារតូច
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូចតាមរយៈអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- ចូលរួមប្រជុំតាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងទៀតដែលគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូចប្រគល់ជូន។

**ប្រការ ៤.-**

លោកជំទាវ លោក លោកស្រីដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០១៨

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក គ.ជ.គ.ក.
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# មាតិកា

**អារម្ភកថា ឯកឧត្តម បណ្ឌិត អ៊ុក រ៉ាប៊ុន**

**អារម្ភកថា ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន**

**១. សេចក្តីផ្តើម** ........ ១

**២. សាវតា** ........ ២

២.១.ក្របខ័ណ្ឌច្បាប់ ........ ២

២.២.គោលនយោបាយថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍ និងការការពារកុមារ ........ ៣

២.៣. ការតាំងចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការអភិវឌ្ឍ និងការការពារកុមារ ........ ៥

**៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការអភិវឌ្ឍ និងការការពារកុមារ** ........ ៦

*ទស្សនៈវិស័យ* ........ ៦

*បេសកកម្ម* ........ ៦

*គោលដៅ* ........ ៧

**៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ ៧

៤.១. ស្ថានភាពកុមារនៅជនបទ ........ ៧

*កុមារ និងអាហារូបត្ថម្ភ* ........ ៧

*កុមារធ្វើការនៅក្នុងវិស័យកសិកម្ម* ........ ៨

*ការទទួលបានការអប់រំ និងជំនាញវិជ្ជាជីវៈក្នុងវិស័យកសិកម្ម* ........ ១១

*ការប្រែប្រួលអាកាសធាតុ និងភាពធន់ទ្រាំរបស់កុមារក្នុងវិស័យកសិកម្ម* ........ ១២

៤.២. វិសាលភាពនៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ ........ ១៣

៤.៣. គោលបំណងជាយុទ្ធសាស្ត្រ និងលទ្ធផល ........ ១៤

៤.៤. យុទ្ធសាស្ត្រ ........ ១៧

៤.៥. ការអនុវត្ត ........ ១៩

៤.៦. ធនធានហិរញ្ញវត្ថុ ........ ២០

៤.៧. ការតាមដាន និងការវាយតម្លៃ ........ ២៣

**៥. ផែនការសកម្មភាព** ........ ២៤

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាមានប្រជាជនចំនួន ១៤,៩៦[១] លាននាក់ ក្នុងនោះប្រជាជនចំនួន ៣៣,៧%[២] មានអាយុក្រោម១៥ឆ្នាំ។ សារៈសំខាន់នៃមនុស្សជំនាន់នេះ ចំពោះស្ថានភាពសង្គម សេដ្ឋកិច្ច និងនយោបាយនៃប្រទេសកម្ពុជា គឺមិនអាចត្រូវបានគេមើលរំលងឡើយ។

កម្ពុជាជាប្រទេសកសិកម្មមួយដែលប្រជាជនចំនួន ៦៤,៦% នៃកម្លាំងពលកម្មសរុបប្រកបរបរចិញ្ចឹមជីវិតដោយការងារកសិកម្ម ការនេសាទ ការប្រមូលផលពីព្រៃឈើ និងអនុផលព្រៃឈើ[៣]។ ជាមួយនឹងនេះ សេដ្ឋកិច្ចជនបទនៅតែមានសារៈសំខាន់ក្នុងការអភិវឌ្ឍជាតិ[៤]។

ប៉ុន្តែការធ្វើកសិកម្ម ការនេសាទ និងអនុផលព្រៃឈើខ្នាតតូចនៅមានការលំបាកសំរាប់ប្រជាជនក្នុងការចិញ្ចឹមជីវិតខ្លួនឯង និងគ្រួសារ។ នៅកម្ពុជា ៩០% នៃកុមារពលកម្មរស់នៅជនបទ និងក្នុងវិស័យកសិកម្មមានប្រមាណត្រឹមតែជាង ៥០% ប៉ុណ្ណោះដែលជាកុមារសកម្មខាងផ្នែកសេដ្ឋកិច្ច។ លើសពី៨០% នៃកុមារពលកម្មមានអាយុចាប់ពី១២ ទៅ១៨ឆ្នាំ [៥]។

ដូច្នេះ ការអភិវឌ្ឍកុមារនៅក្នុងវិស័យកសិកម្ម គឺមិនត្រឹមគ្រាន់តែជាការបង្ការទប់ស្កាត់ពលកម្មកុមារ ឬបញ្ហាប្រឈមរបស់កុមារទៅនឹងសារធាតុគីមី ឬស្ថានភាពប្រកបដោយគ្រោះថ្នាក់ក្នុងទម្រង់ផ្សេងៗ ប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយគាំទ្រដល់ស្ថានភាពអាហារូបត្ថម្ភកុមារ និងយុវជនដែលពាក់ព័ន្ធក្នុងវិស័យកសិកម្មឲ្យមានភាពប្រសើរឡើង។ លើសពីនេះ ទាមទារឲ្យមានការផ្តល់ដល់កុមារ និងយុវជននូវជំនាញដែលចាំបាច់សម្រាប់ការងាររបស់ពួកគេក្នុងវិស័យកសិកម្ម។ ជំនាន់ក្មេងៗដែលប្រកបទៅដោយចំណេះដឹងគ្រប់គ្រាន់ អាហារូបត្ថម្ភគ្រប់គ្រាន់ គឺជាស្ថានភាពដ៏ចាំបាច់មួយក្នុងការកែប្រែវិស័យកសិកម្មទៅជាវិស័យមួយដែលមាននិរន្តរភាព និងភាពរីកចម្រើន។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍និងការពារកុមារនៅក្នុងវិស័យកសិកម្មនេះ បានអះអាងអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលើកកម្ពស់ស្ថានភាពការអភិវឌ្ឍនិងការការពារកុមារ ទប់ស្កាត់ពលកម្មកុមារនៅក្នុងវិស័យកសិកម្ម រួមទាំងនៅក្នុងអនុវិស័យផ្សេងៗទៀតផងដែរ ហើយនិងការពារពួកគេពីគ្រោះថ្នាក់ទាំងឡាយដូចជាការប្រើប្រាស់ថ្នាំពុល និងជីគីមីកសិកម្ម។ នេះគឺជាគោលនយោបាយ និងក្របខណ្ឌ័យុទ្ធសាស្ត្រដំបូងគេបង្អស់ស្តីពីការអភិវឌ្ឍ និងការការពារកុមារ ដែលបានតាក់តែងឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឯកសារនេះ ក៏ត្រូវបានបង្កើតឡើង ក្រោមកិច្ចពិភាក្សាជាមួយនឹងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលផងដែរ។

---

១. ជំរឿនកសិកម្មឆ្នាំ២០១៣

២. យោងទៅលើជំរឿនប្រជាជនចុងក្រោយ ឆ្នាំ២០០៨

៣. យោងទៅលើជំរឿនកសិកម្ម ឆ្នាំ២០១៣

៤. យោងទៅលើជំរឿនកសិកម្មចុងក្រោយ ក្នុងឆ្នាំ២០១៣ វិស័យកសិកម្មរួមចំណែក ៣១.៦%នៃផលិតផលជាតិសរុប (GDP)

៥. ការអង្កេតពលកម្មកុមារ (២០១២)

## ២. សាវតា

### ២.១.ក្របខ័ណ្ឌច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងមាត្រា៤៨ បានធានាដល់សិទ្ធិកុមារ ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការការពារនៅក្នុងពេលសង្គ្រាម និងសិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងផ្លូវភេទ។ រដ្ឋមានកាតព្វកិច្ច *“ ការពារកុមារពីទង្វើដែលធ្វើឱ្យអន្តរាយដល់ឱកាសសម្រាប់ការអប់រំ សុខភាព និងសុខុមាលភាពរបស់កុមារ”* [៦]។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ អនុសញ្ញាអាយុអប្បបរមា នៃអង្គការពលកម្មអន្តរជាតិ (លេខ១៣៨) ឆ្នាំ១៩៩៩ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងឆ្នាំ២០០៥។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ បានកំណត់យ៉ាងច្បាស់ថាកុមារ គឺជាមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។ អាយុរបស់កុមារ គឺជាកត្តាដ៏មានសារៈសំខាន់សម្រាប់ការកំណត់ពីភាពខុសៗគ្នា រវាងការងារដែលសមរម្យ ទៅនឹងកំលាំងពលកម្ម របស់ពួកគេដូចដែលមាននៅក្នុងអនុសញ្ញាអាយុអប្បរមា នៃអង្គការពលកម្មអន្តរជាតិ ឆ្នាំ១៩៧៣ (លេខ ១៣៨)។

ច្បាប់ស្តីពីការងាររបស់កម្ពុជា (១៩៩៧) បានកំណត់អាយុអប្បរមាសំរាប់ការងារនៅត្រឹមអាយុ១៥ឆ្នាំ ដែលកុមារអាយុចាប់ពី១២ដល់១៥ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យធ្វើការងារស្រាលៗ[៧]។ សេចក្តីប្រកាសស្តីពីការហាមឃាត់ពលកម្មកុមារប្រកបដោយគ្រោះថ្នាក់(២០០៤) បានកំណត់ពីប្រភេទការងារប្រកបដោយគ្រោះថ្នាក់ចំនួន៣៨ប្រភេទរួមមាន ការងារនៅក្រោមដី ការលើកដាក់ លីសែង ឬរំកិលវត្ថុធ្ងន់ៗ ការងារនៅក្នុងសមុទ្រទឹកជ្រៅ ការនេសាទនៅកណ្តាលសមុទ្រ ព្រមទាំងការកាន់និងបាញ់ថ្នាំសម្លាប់សត្វល្អិត ឬថ្នាំកំចាត់ស្មៅ។ ការងារគ្រោះថ្នាក់ទាំងនេះ ត្រូវបានហាមឃាត់ដល់កុមារអាយុក្រោម១៨ឆ្នាំ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសថ្នាក់ក្រសួងចំនួន១២ ស្តីពីល័ក្ខខ័ណ្ឌការងារទៅតាមប្រភេទបរិយាកាសការងារខុសៗគ្នារបស់កុមារ រួមមានការនេសាទនៅតាមសមុទ្រនិងលើដីគោក ផលិតកម្មអំបិល ដំឡូងមី និងថ្នាំជក់[៨]។ ទន្ទឹមគ្នានេះ ពលកម្មកុមារក៏ត្រូវបានហាមឃាត់ដោយច្បាប់របស់ជាតិស្របទៅនឹងអនុសញ្ញាអន្តរជាតិផងដែរ។

---

៦. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៨

៧. ប្រកាសលេខ ០០២/០៨ (២០០៨) ស្តីពីការងារស្រាល សម្រាប់កុមារអាយុ ១២ទៅ ១៥ឆ្នាំ៖ ការងារស្រាលៗគឺជាប្រភេទការងារដែលមិនបង្កគ្រោះថ្នាក់ការអភិវឌ្ឍផ្លូវចិត្ត និងរូបរាងកាយកុមារ និងមិនជះឥទ្ធិពលដល់ការសិក្សារបស់ពួកគេនៅសាលារៀនការចូលរួមក្នុងកម្មវិធីណែនាំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឯកភាពដោយអាជ្ញាធរមានសមត្ថកិច្ច ឧទាហរណ៍ ការងារចិញ្ចឹមសត្វដែលស្រាលៗ ក្នុងវិស័យកសិកម្ម ការថែទាំសត្វ (តែទោះបីជាយ៉ាងណាក៏ដោយមិនមែនជាការចាប់ ឬសម្លាប់សត្វទាំងនោះទេ) ការងារដាំដុះ ប្រមូលផលដំណាំ បេះផ្លែឈើ (តែមិនមែនឡើងដើមឈើទេ) និងការលាងសំអាតជាដើម។ កំឡុងពេលធ្វើការគឺមិនអនុញ្ញាតលើសពី៤ម៉ោងទេ សម្រាប់ថ្ងៃសិក្សា។

៨. ការលុបបំបាត់ប្រឆាំងនឹងនឹងកុមារមិនឲ្យធ្វើការនៅពេលយប់ ហាមឃាត់កុមារពីការធ្វើការងារដែលមានគ្រោះថ្នាក់ ការងារនេសាទនៅសមុទ្រ ស្ថានភាពការងារ និងការរស់នៅក្នុងចំការ ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ផលិតកម្មអំបិល ឡឥដ្ឋ ការកំណត់ប្រភេទការងារស្រាលៗសម្រាប់កុមារ ដែលមានអាយុ ១២ទៅ១៥ ឆ្នាំ ស្ថានភាពការងារសម្រាប់កុមារ ក្នុងចំការដំឡូងមី ក្នុងការនេសាទទឹកសាប កសិកម្ម និង ចំការថ្នាំជក់

**និយមន័យនៃពលកម្មកុមារ**

ពលកម្មកុមារ គឺត្រូវបានកំណត់ថាជាការងារដែលធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពកុមារ ឬជាឧបសគ្គដល់ការអប់រំ ការអភិវឌ្ឍ និងជីវភាពរបស់ពួកគេនាពេលអនាគត។ នេះជាការងារទាំងឡាយណាដែលបង្កការខូចខាតទៅដល់ការអភិវឌ្ឍរូបរាងកាយ សង្គម ផ្លូវចិត្ត ប្រាជ្ញាស្មារតី ឬក៏សតិអារម្មណ៍របស់កុមារ។ (អនុសញ្ញាអង្គការពលកម្មកុមារ លេខ១៣៨)

**ពិធីសារអន្តរជាតិស្តីពីពលកម្មកុមារ**

អនុសញ្ញាអាយុអប្បបរមា លេខ១៣៨ នៃអង្គការពលកម្មអន្តរជាតិ បានកំណត់ពីអាយុទាបបំផុតសម្រាប់ប្រភេទការងារផ្សេងៗគ្នាដូចខាងក្រោម៖

-អាយុចាប់ពី១៣ឆ្នាំ សម្រាប់ការងារស្រាលៗ

-អាយុចាប់ពី១៥ឆ្នាំ សម្រាប់ការងារធម្មតាៗ

-អាយុ ១៨ ឆ្នាំសម្រាប់ការងារដែលមានហានិភ័យ

អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ១៨២ ក៏បានបង្ហាញផងដែរពីទម្រង់ផ្សេងៗ នៃពលកម្មកុមារ។

**ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

**អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ ឆ្នាំ១៩៩៩ ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (លេខ ១៨២) បានកំណត់និយមន័យទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅក្នុងមាត្រា៣ដូចខាងក្រោម៖**

**ការងារទាំងឡាយណាដែលធ្វើជាប្រចាំ ឬតាមកាលៈទេសៈ ដែលអាចប៉ះពាល់ទៅដល់ សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ (ការងារមានហានិភ័យ)**

-រាល់ទម្រង់នៃទាសករ ឬការអនុវត្តទាំងឡាយណាដែលដូចគ្នាទៅនឹងទាសករ ដូចជា ការលក់ និងជួញដូរកុមារជាអ្នកបម្រើ និងជាខ្ញុំកញ្ជះដើម្បីសងបំណុល និងជាកម្មករដែលទទួលរងនូវការបង្ខិតបង្ខំ រួមទាំងការបង្ខិតបង្ខំឲ្យចូលរួមបម្រើកងទ័ពនៅកំឡុងពេលមានជម្លោះប្រដាប់អាវុធ។

-ការប្រើប្រាស់ ការទទួលយក ឬការឲ្យកុមារធ្វើពេស្យាចារ ផលិតជាសម្ភារអាសអាភាស ឬការសំដែងរឿងអាសអាភាស និង

-ការប្រើប្រាស់ ការផ្តល់ឲ្យ ឬការទទួលកុមារសម្រាប់សកម្មភាពខុសច្បាស់ផ្សេងៗ ជាពិសេសសម្រាប់ការផលិត និងជួញដូរថ្នាំញៀន ដូចដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ។

សហគមន៍អន្តរជាតិ បានទទួលស្គាល់អំពីសេចក្តីត្រូវការជាបន្ទាន់ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ តាមរយៈការផ្តល់សច្ចាប័នស្ទើរតែជាសាកល ដោយប្រទេសចំនួន១៧៩ នាពេលបច្ចុប្បន្ននេះ ហើយគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបានកំណត់គោលដៅក្នុងការលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរទាំងនេះឲ្យអស់ត្រឹមឆ្នាំ២០២៥។

## ២.២.គោលនយោបាយថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍ និងការការពារកុមារ

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសអំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយលើការអភិវឌ្ឍកុមារតាមរយៈគោលនយោបាយ និងផែនការជាតិរួមមាន គោលនយោបាយជាតិស្តីពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលបានអនុម័តនៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ផែនការជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ ផែនការជាតិសម្រាប់អភិវឌ្ឍន៍កុមារ (២០១៥ - ២០១៨) តាមរយៈក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) និងគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រផ្សេងៗ ទៀត។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់កំណើន ការងារ សមភាព និងប្រសិទ្ធភាព នៅតំណាក់កាលទី៣ (២០១៤-២០១៨) បានកំណត់នូវទិសដៅគោលនយោបាយយ៉ាងទូលំទូលាយ សម្រាប់ការធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ (FSN) និងបានកំណត់ពីអាទិភាព សម្រាប់បង្កើននូវបរិមាណ លទ្ធភាពទទួលបានការប្រើប្រាស់ និងស្ថេរភាពនៃស្បៀងអាហារ ដូចដែលបាន បញ្ជាក់ក្នុងជ្រុងមួយនៃមុំយុទ្ធសាស្ត្រនេះ ដោយផ្តោតទៅលើប្រពលវប្បកម្ម និងពិពិធកម្មកសិកម្ម កំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការបង្កើនសុខភាព និងអាហារូបត្ថម្ភ និងការបង្កើតនូវសំណាញ់សុវត្ថិភាពសង្គម។

ទស្សនៈវិស័យរយៈពេលវែង គឺ ប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពខាងផ្នែករូបរាងកាយ សង្គម និងសេដ្ឋកិច្ច ក្នុងការទទួលបាននូវស្បៀងអាហារគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាព និងមានសារធាតុចិញ្ចឹម គ្រប់ពេលវេលា ដើម្បីបំពេញតម្រូវការ និងចំណង់ចំណូលចិត្តអាហាររបស់ពួកគេ ហើយនិងការប្រើប្រាស់អាហារឲ្យបានសមស្រប សម្រាប់ជីវិតប្រកបដោយផលិតភាពនិងសុខភាព។

លទ្ធផលនេះ នឹងទទួលបានតាមរយៈគោលបំណងចំនួន៣ ដូចខាងក្រោមៈ

*<u>គោលបំណងទី១</u>: គ្រួសារដែលមានអសន្តិសុខស្បៀងនឹងអាចបង្កើនបរិមាណស្បៀង និងការទទួលបានស្បៀងគ្រប់គ្រាន់ តាមរយៈការធ្វើកសិកម្មចម្រុះ និងកាន់តែមានផលិតភាព រួមនិងផលិតកម្មសត្វ ការនេសាទ និងព្រៃឈើ ដែលប្រកបដោយចេរភាព និងតាមរយៈការងារមិនមែនកសិកម្ម និងឱកាសរកចំណូលផ្សេងទៀត។*

*<u>គោលបំណងទី២</u>: ប្រជាជនកម្ពុជាបង្កើនការប្រើប្រាស់ស្បៀងអាហាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព កាត់បន្ថយកង្វះអាហារូបត្ថម្ភមាតា និងកុមារ និងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច។*

*<u>គោលបំណងទី៣</u>: បង្កើនសន្តិសុខស្បៀងទាក់ទងនឹងការការពារផ្នែកសង្គម និងលើកកម្ពស់សមត្ថភាពគ្រួសារក្រីក្រ និងងាយរងគ្រោះដើម្បីទប់ទល់នឹងហានិភ័យ និងភាពតានតឹងផ្សេងៗ ដោយបង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀងអាហាររបស់ពួកគេ[៩]។*

ក្រុមការងារបច្ចេកទេសស្តីពីការការពារផ្នែកសង្គម និងសន្តិសុខស្បៀង ដែលដឹកនាំដោយប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទជាអ្នកទទួលខុសត្រូវសម្របសម្រួលយុទ្ធសាស្ត្រនេះ។ តួនាទីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺមានសារៈសំខាន់ណាស់ក្នុងការគាំទ្រឱ្យសម្រេចបាននូវគោលបំណងទី១ខាងលើ តាមរយៈការបង្កើនពិពិធកម្មកសិកម្ម និងសមាហរណកម្មទីផ្សារនៃគ្រួសារកសិករខ្នាតតូច។

យន្តការដែលទទួលបន្ទុកក្នុងការលើកកម្ពស់ និងការតាមដានការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលបានផ្តល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា គឺក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥។ ក្រុមប្រឹក្សានេះ ត្រូវបានដឹកនាំដោយក្រសួងសង្គមកិច្ច ហើយបានបញ្ជាក់យ៉ាងច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធក្នុងការធានាបាននូវការអនុវត្តរាល់មាត្រានៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

---

៩. ព្រះរាជាណាចក្រកម្ពុជា យុទ្ធសាស្ត្រជាតិ សម្រាប់អាហារូបត្ថម្ភ និងសន្តិសុខស្បៀង (២០១៤-២០១៨) រៀបចំដោយ CARD ក្នុងកិច្ចប្រឹក្សាយោបលជាមួយនឹងក្រុមការងារបច្ចេកទេស សម្រាប់ការការពារសង្គម និងអាហារូបត្ថម្ភ និងសន្តិសុខស្បៀង ២០១៤

លើសពីនេះទៅទៀត គោលនយោបាយជាតិស្តីពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១០ បានបញ្ជាក់យ៉ាងច្បាស់អំពី ទស្សនៈវិស័យមួយដែលថា *" កុមារកម្ពុជាទាំងអស់ ចាប់តាំងពីពេលចាប់កំណើតរហូតដល់អាយុក្រោម៦ឆ្នាំ ជាពិសេស កុមារដែលងាយរងគ្រោះ និងកុមារក្រីក្រ នឹងត្រូវទទួលបានសេវាថែទាំ និងអភិវឌ្ឍន៍..." (ទីស្តីការគណៈរដ្ឋមន្ត្រី ២០១០)*។ គោលនយោបាយក៏បានបញ្ជាក់យ៉ាងច្បាស់ពីយុទ្ធសាស្ត្រដើម្បីសម្រេចទស្សនៈវិស័យនេះ ឧទាហរណ៍ដូចជា ការបង្កើតក្របខ័ណ្ឌ និងយន្តការច្បាប់ សម្រាប់បញ្ជាក់ឱ្យកាន់តែច្បាស់លាស់ពីករណីកិច្ចរបស់អ្នកពាក់ព័ន្ធសំខាន់ៗ និងការអនុវត្តគោលនយោបាយ ការធ្វើឱ្យប្រសើរឡើងនៃយន្តការតាមដាន និងសម្របសម្រួលលើការកសាងសមត្ថភាពសម្រាប់អ្នកអនុវត្តកម្មវិធី និងមាតាបិតារបស់កុមារ និងការពង្រីកការទទួលបានសេវាថែទាំសុខភាពសំខាន់ៗ និងសេវាអប់រំនៅក្នុងចំណោមស្ត្រីមានផ្ទៃពោះ ទារក និងកុមារវ័យក្មេងៗ។ ដើម្បីបង្កលទ្ធភាពក្នុងការអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រទាំង៩ នៃគោលនយោបាយជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ផែនការសកម្មភាពជាតិដែលជាក់ស្តែង និងប្រាកដនិយមមួយ ស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ២០១៤-២០១៨ ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៤។

ផែនការសកម្មភាពនេះ នឹងរួមចំណែកក្នុងការសម្រេចទិសដៅនៃផែនការអភិវឌ្ឍន៍សហសវត្សន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រអប់រំ ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្ររបស់វិស័យផ្សេងៗទៀត។ អាទិភាពនៃផែនការសកម្មភាពជាតិទាំងនេះ រួមមានការចងក្រងជាយន្តការ និងក្របខ័ណ្ឌច្បាប់ ការធ្វើឲ្យប្រសើរឡើងនូវយន្តការតាមដាន និងវាយតម្លៃ ការអភិវឌ្ឍសមត្ថភាព ការពង្រីកសេវាកម្មសុខភាព អប់រំ និងការគាំពារស្ត្រី និងកុមារតូច ជាពិសេស ការផ្តល់ជាបឋមនូវការអប់រំជាមូលដ្ឋាន ចំពោះកុមារក្មេងៗ ជាមួយនឹងការផ្តោតជាពិសេសទៅលើកុមារក្មេងៗដែលជាជនរងគ្រោះ ជនងាយរងគ្រោះ និងកុមារដែលរស់នៅក្នុងគ្រួសារក្រីក្រ។

គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ក៏មានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិកមួយដែលទទួលបន្ទុកក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពជាតិ គាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៤-២០១៨ នេះផងដែរ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំការអនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (២០០៨-២០១២) ហើយតាំងពីឆ្នាំ ២០១២ ផែនការសកម្មភាពថ្មីមួយត្រូវបានបញ្ចប់សព្វគ្រប់។ ផែនការសកម្មភាព គឺជាពហុវិស័យ ដែលរួមមានការការពារផ្នែកពលកម្ម ការអប់រំ សង្គមកិច្ច និងកសិកម្ម ជាក្របខ័ណ្ឌសម្រាប់អ្នកពាក់ព័ន្ធជាច្រើន ធ្វើការឆ្លើយតបទៅនឹងពលកម្មកុមារ។ ផែនការសកម្មភាពជាតិថ្មីមួយនេះ នឹងតម្រូវឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការបរិយាយយ៉ាងល្អិតល្អន់ និងអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅក្នុងអនុវិស័យកសិកម្ម ជលផល ព្រៃឈើ កសិ-ឧស្សាហកម្ម និងពាណិជ្ជូបនីកម្មកសិកម្ម។

## ២.៣. ការតាំងចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការអភិវឌ្ឍ និងការការពារកុមារ

កម្មវិធី និងគម្រោងកសិកម្មមានឥទ្ធិពលលើស្ថានភាពកុមារតាមមធ្យោបាយខុសៗគ្នា ៖ តាមរយៈការលើកកម្ពស់ផលិតកម្មកសិកម្មចម្រុះ ដែលអាចបង្កើនអាហារូបត្ថម្ភរបស់កុមារ ការណែនាំបច្ចេកទេសកសិកម្ម និងបច្ចេកវិទ្យាថ្មីៗ ដែលអាចកាត់បន្ថយ ឬបង្កើនបន្ទុកការងារ និងផ្តល់ហានិភ័យដល់កុមារ។ ដូច្នេះ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងការការពារកុមារ ហើយនេះគឺជាផ្នែកមួយនៃយន្តការសម្របសម្រួលផ្សេងៗ ដែលធ្វើការលើការអភិវឌ្ឍនិងការការពារកុមារ។

ដោយយោងទៅលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងផ្នែកមួយដែលស្តីអំពីក្របខ័ណ្ឌយុទ្ធសាស្រ្ត សម្រាប់ការអភិវឌ្ឍនិងការការពារកុមារនៅក្នុងវិស័យកសិកម្ម ដោយលើកឡើងថា “ ក្រសួងនឹងបង្កើតក្របខ័ណ្ឌច្បាប់ និងយន្តការគាំទ្រ កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធ លើកកម្ពស់ការយល់ដឹងអំពីការអភិវឌ្ឍនិងការការពារកុមារ ដល់មាតាបិតា អាណាព្យាបាល បង្កើតនិងពង្រឹងយន្តការតាមដាន វាយតម្លៃ និងកៀរគរវាល់ធនធាន ដើម្បីទ្រទ្រង់ដល់ការលើកកម្ពស់ការអភិវឌ្ឍនិងការការពារកុមារនៅក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព”។

ដើម្បីលើកកម្ពស់ការអភិវឌ្ឍនិងការការពារកុមារប្រកបដោយប្រសិទ្ធភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមយ៉ាងសកម្មនៅក្នុងយន្តការសម្របសម្រួលថ្នាក់ជាតិផ្សេងៗ រួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ដែលមានក្រសួងចំនួន១៣ ជាសមាជិក។ ក្នុងនាមជាសមាជិកសកម្មមួយនៃគណៈកម្មាធិការជាតិនេះ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៤។ គណៈកម្មាធិការនេះ មានអាណត្តិ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអភិវឌ្ឍនិងការការពារកុមារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរួមចំណែកក្នុងការរៀបចំនិងអនុវត្តគោលនយោបាយជាតិ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច។

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការក្នុងកិច្ចសហការជាមួយនឹងក្រុមការងារយេនឌ័រ និងកុមារ នៅថ្នាក់កណ្តាល និងជនបង្គោលយេនឌ័រ និងកុមារ នៅអង្គភាពក្រោមឱវាទក្រសួង និងថ្នាក់ខេត្ត ដើម្បីលើកកម្ពស់ការសម្របសម្រួល និងតាមដានការអនុវត្ត គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្មនេះ។

## ៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការអភិវឌ្ឍ និងការការពារកុមារ

### *ទស្សនៈវិស័យ*

ទស្សនៈវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការអភិវឌ្ឍ និងការការពារកុមារ គឺ ” កុមារនៅក្នុងវិស័យកសិកម្ម មានសុខភាពល្អ មានការអភិវឌ្ឍ ហើយសិទ្ធិរបស់ពួកគេត្រូវបានការពារ”[១០]។

### *បេសកកម្ម*

បេសកកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការអភិវឌ្ឍ និងការការពារកុមារ គឺ“ក្រសួងនឹងបង្កើតក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងយន្តការគាំទ្រ កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធលើកកម្ពស់ការយល់ដឹងអំពីការការពារ និងការអភិវឌ្ឍកុមារ ដល់មាតាបិតា អាណាព្យាបាល បង្កើត និងពង្រឹងយន្តការតាមដាន វាយតម្លៃ និងកៀរគរវាល់ធនធាន ដើម្បីទ្រទ្រង់ដល់ការលើកកម្ពស់ការការពារ និងការអភិវឌ្ឍកុមារនៅក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព”។

១០.ការអភិវឌ្ឍកុមារជាទូទៅសំដៅទៅលើការអភិវឌ្ឍផ្នែកប្រាជ្ញាស្មារតី សង្គម អារម្មណ៍ និងរាងកាយ (ការអភិវឌ្ឍចិត្តសាស្រ្ត គឺគ្របដណ្តប់លើអារម្មណ៍ និងប្រាជ្ញាស្មារតី)។ ការការពារកុមារជាទូទៅសំដៅទៅលើការបង្ការ និងការឆ្លើយតបទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ

*គោលដៅ*

គោលដៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការអភិវឌ្ឍ និងការការពារកុមារ គឺ" លើកកម្ពស់ការការពារនិងការអភិវឌ្ឍកុមារ នៅក្នុងវិស័យកសិកម្ម ជាពិសេសកុមារងាយរងគ្រោះនៅក្នុងគ្រួសារកសិករក្រីក្រ " ។

## ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ៤.១. ស្ថានភាពកុមារនៅជនបទ

បើទោះជាស្ថានភាពរស់នៅរបស់កុមារនៅតំបន់ជនបទមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះក៏ដោយ ក៏ស្ថានភាពនេះនៅតែគួរឱ្យព្រួយបារម្ភនៅឡើយ។ កុមារ ១នាក់ក្នុងចំណោមកុមារ ២៩នាក់ មិនអាចរស់រានមានជីវិតបាន ក្នុងរយៈពេលប្រាំឆ្នាំដំបូង នៃជីវិតរបស់ពួកគេ[១១] និងជាងពាក់កណ្តាលនៃចំនួនប្រជាជនដែលស្ថិតនៅក្រោមអាយុ១៨ឆ្នាំ នៅតំបន់ជនបទរស់នៅក្នុងភាពក្រីក្រ។

*កុមារ និងអាហារូបត្ថម្ភ*

ជារួម កង្វះអាហារូបត្ថម្ភរបស់មាតា និងកុមារ ត្រូវបានកាត់បន្ថយបន្តិចម្តងៗចាប់តាំងពីឆ្នាំ ២០០៥ មកម្ល៉េះ ប៉ុន្តែការផ្តល់អាហារមិនគ្រប់គ្រាន់ដល់ម្តាយ និងកុមារមានភាពខុសគ្នាខ្លាំងតាមតំបន់និងក្រុមមនុស្សផ្សេងៗគ្នានៃសង្គម។ នៅក្នុងឆ្នាំ ២០១៤ មាន ៣៤% នៃកុមារដែលមានអាយុក្រោម៥ឆ្នាំនៅតំបន់ជនបទ បានទទួលរងនូវការខ្វះអាហារជាលក្ខណៈរ៉ាំរ៉ៃ (ក្រិន) ធៀបទៅនឹង២៤%នៅក្នុងតំបន់ទីប្រជុំជន[១២]។ នៅក្នុងខេត្តចំនួន១៣ ជាទូទៅអត្រានៃកុមារដែលមានសុខភាពខ្សោយមានច្រើនជាង ១0% ដែលត្រូវបានគេចាត់ទុកថាជាបញ្ហា "ធ្ងន់ធ្ងរ" ដោយយោងទៅលើការចាត់ថ្នាក់របស់អង្គការសុខភាពពិភពលោកស្តីពីភាពធ្ងន់ធ្ងរ នៃបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវនេះ[១៣]។

ស្ថិតនៅក្រោមភាពខ្វះខាតសារធាតុចិញ្ចឹម និងអាហារូបត្ថម្ភក្នុងកំឡុងពេលនៃកុមារភាពដំបូង បានជះឥទ្ធិពលដល់ជីវិតទាំងមូលរបស់បុគ្គលម្នាក់ៗ ដែលនាំឱ្យការអភិវឌ្ឍប្រាជ្ញាស្មារតី និងលទ្ធផលនៃការអប់រំមានលក្ខណៈខ្សោយ ហើយវានឹងឈានទៅដល់ការរាំងស្ទះយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍធនធានមនុស្ស។ ទោះបីជាមានការលំបាកក្នុងការដាក់តម្លៃជារូបិយវត្ថុទៅលើការផ្តល់អាហារមិនគ្រប់គ្រាន់ក៏ដោយក៏ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) UNICEF និងកម្មវិធីស្បៀងអាហារពិភពលោក (WFP) បានព្យាករថា ប្រទេសកម្ពុជាត្រូវបានបាត់បង់ប្រមាណជា៤០០ លានដុល្លានៅក្នុងផលទុនសរុបក្នុងស្រុក (GDP) ជារៀងរាល់ឆ្នាំដោយសារតែកង្វះអាហារូបត្ថម្ភពេញមួយវដ្តជីវិតរបស់ប្រជាជនកម្ពុជា។ កង្វះ មីក្រូសារធាតុចិញ្ចឹមបានបង្ហាញពីការដាក់បន្ទុកដល់ជាតិ គិតជាទឹកប្រាក់ប្រមាណជាង ២០០លានដុល្លា ជារៀងរាល់ឆ្នាំ[១៤]។

បញ្ហាអាហារូបត្ថម្ភ គឺជាការទទួលខុសត្រូវជាចម្បងរបស់ក្រសួងសុខាភិបាល តែដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភរបស់មាតា និងកុមារ ចាំបាច់តម្រូវឲ្យមានការអនុម័តអភិក្រមពហុវិស័យ។

---

១១. វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសុខាភិបាល (២០១៥) ការអង្កេតពីសុខភាព និងអត្រានុកូលសាស្ត្រកម្ពុជា ២០១៤

១២. វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសុខាភិបាល (២០១៥) ការអង្កេតពីសុខភាព និងអត្រានុកូលសាស្ត្រកម្ពុជា ២០១៤

១៣. អង្គការ UNI CEF ( ) ភាពចាំបាច់ នៃការដោះស្រាយលំហូរសាច់ប្រាក់ និងអាហារូបត្ថម្ភកុមារ នៅកម្ពុជា

១៤. យុទ្ធសាស្ត្រជាតិ សម្រាប់អាហារូបត្ថម្ភ និងសន្តិសុខស្បៀង ២០១៤-២០១៨ P.2

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលទ្ធភាពក្នុងការធ្វើការងារដោយផ្ទាល់ជាមួយកសិករ និងផលិតកម្មស្បៀងអាហាររបស់ពួកគេ។ បើយោងទៅតាមគោលនយោបាយជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូចបានលើកឡើងថា "ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គប្បីលើកទឹកចិត្ត និងបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម សម្រាប់ឪពុកម្ដាយ អាណាព្យាបាល និងអ្នកគ្រប់គ្រងតាមរយៈមន្ត្រីផ្សព្វផ្សាយកសិកម្មនៅគ្រប់កម្រិតទាំងអស់" ។

### *កុមារធ្វើការនៅក្នុងវិស័យកសិកម្ម*

ការប៉ាន់ប្រមាណមួយស្ដីពីពលកម្មកុមារបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា និងអង្គការពលកម្មអន្តរជាតិបានបង្ហាញថា ១៩,១%នៃកុមារកម្ពុជាអាយុចាប់ពី៥ឆ្នាំដល់១៧ឆ្នាំ (៧៥៥ ២៤៥) គឺជាកុមារសកម្មខាងផ្នែកសេដ្ឋកិច្ច។ កុមារជាងពាក់កណ្ដាល (៤២៩ ៣៨០ ឬ៥៦,៩%) ធ្វើពលកម្ម ដែលភាគច្រើន (៣១,៣%) កំពុងធ្វើការងារក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់[១៥]។ កុមារ ២៧៦ ០០០នាក់ ដែលកំពុងធ្វើការងារមានអាយុតិចជាង១៥ឆ្នាំ។ ភាគច្រើននៃកុមារសកម្មខាងផ្នែកសេដ្ឋកិច្ចនៅប្រទេសកម្ពុជា (៨៦,៧%) រស់នៅតាមតំបន់ជនបទ។ កុមារ៩នាក់នៅក្នុងចំណោមកុមារធ្វើពលកម្ម១០នាក់ ធ្វើការជាង ៤៨ ម៉ោងក្នុងមួយសប្ដាហ៍។ កិច្ចការ ម៉ោងធ្វើការងារ និងការប្រឈមនឹងគ្រោះថ្នាក់មានភាពខុសគ្នារវាងក្មេងប្រុស និងក្មេងស្រី។ ជាឧទាហរណ៍ ក្មេងប្រុសធ្វើការងារខាងផ្នែកនេសាទមានសមមាត្រខ្ពស់ជាងក្មេងស្រីដែលភាគច្រើនធ្វើការខាងផ្នែកកសិកម្មផង និងការងារផ្ទះផង។

### *កុមារក្នុងការងារកសិកម្មជាលក្ខណៈគ្រួសារ*

កិច្ចការរបស់ពួកគេមានចាប់ពីការរៀបចំដី និងការសាបគ្រាប់ពូជ ដកស្ទូង ការចិញ្ចឹមមាន់ ការផ្ដល់ចំណីសត្វពាហណៈនិងការនេសាទត្រី។ ការងារគ្រោះថ្នាក់ គឺទាក់ទងទៅនឹងការបាញ់ថ្នាំគីមីកសិកម្មឬប្រើឧបករណ៍មុតស្រួច លើកដាក់វត្ថុធ្ងន់ៗ សត្វទិច ឬខាំ ការបង្ករោគលើស្បែក ការប៉ះពាល់ផ្សេងៗដោយសីតុណ្ហភាព។ ប៉ុន្តែបញ្ហាចំបង គឺកុមារចាប់ផ្ដើមធ្វើការងារនៅក្រោមអាយុអប្បបរមាដែលកំណត់ដោយច្បាប់ ហើយកុមារដែលធ្វើការច្រើនម៉ោងពេកក្នុងមួយថ្ងៃៗ ធ្វើឲ្យរាំងស្ទះដល់ឱកាសរបស់ពួកគេសម្រាប់ការទទួលប្រយោជន៍ពីការអប់រំ។

ច្បាប់នៃប្រទេសកម្ពុជាមិនអាចដោះស្រាយចំពោះបញ្ហាការងារកុមារនៅក្នុងផ្នែកកសិកម្មជាលក្ខណៈគ្រួសារនោះបានទេ ប៉ុន្តែច្បាប់បានកម្រិតចំនួនម៉ោងការងារសម្រាប់កុមារមានអាយុលើសពី១២ឆ្នាំ ដែលអាចបំពេញការងារបាន[១៦]។

### *កុមារក្នុងការងារផ្នែកនេសាទ*

កុមារចាប់ផ្ដើមធ្វើការងារជាអ្នកនេសាទត្រីទឹកសាបដើម្បីចិញ្ចឹមជីវិតតាំងពីអាយុ១០ឆ្នាំ។ នៅតំបន់ទន្លេសាប អ្នកនេសាទត្រូវធ្វើដំណើរជាច្រើនគីឡូម៉ែត្រដើម្បីនេសាទត្រី ដូច្នេះពួកគេត្រូវស្នាក់នៅលើទឹកមួយយប់ ឬពីរយប់ដោយយកក្មេងទៅជាមួយផងដែរ។ បើទោះជាកុមារនៅរៀនក៏ដោយ ក៏ពួកគេទៅរៀនមិនជាប់លាប់ ឬបោះបង់ចោលការសិក្សាមួយរយៈតែម្ដង ដែលនាំឲ្យការវិលត្រឡប់ចូលក្នុងសាលារបស់ពួកគេជួបបញ្ហាប្រឈមកាន់តែច្រើន។

---

១៥. វិទ្យាស្ថានជាតិស្ថិតិ/ អង្គការពលកម្មអន្តរជាតិ ២០១៣ ការអង្កេតស្ដីពីពលកម្មកុមារ ថ្នាក់ជាតិ

១៦. ៤ម៉ោង នៃថ្ងៃរៀននៅសាលា

ហានិភ័យចម្បងនៃកុមារដែលបំពេញពលកម្មនៅក្នុងផ្នែកនេសាទ គឺការប្រឈមនឹងការមានរបួសដោយមុតឆ្អឹងត្រី បន្លារ ប្រឈមនឹងការរលាកដោយកំដៅថ្ងៃ ពីព្រោះតែធ្វើការច្រើនម៉ោងនៅលើបឹង ឬទន្លេ និងនៅក្នុងទឹកយូរពេក។

*កុមារក្នុងការងារដាំដុះ*

កុមារនៅតែត្រូវបានគេជួលឱ្យធ្វើការងារនៅក្នុងចំការកៅស៊ូ ចំការអំពៅ ចំការដំឡូងមី និងចំការថ្នាំជក់។ ខណៈពេលមានប្រកាសលេខ៣០៦ ស្តីពីពលកម្មកុមារនៅក្នុងការដាំដុះរួចហើយនោះ ជាមួយនឹងបញ្ជីរដែលបរិយាយយ៉ាងទូលំទូលាយមួយពីគ្រោះថ្នាក់ ក៏ពលកម្មកុមារនៅតែមានដដែល។ ការប៉ាន់ប្រមាណរហ័សមួយរបស់អង្គការពលកម្មអន្តរជាតិ (ILO) ទៅលើពលកម្មកុមារនៅក្នុងចំការអំពៅបានបង្ហាញថា មានការប្រើប្រាស់ពលកម្មកុមារ ដោយរួមមានការឲ្យកុមារបំពេញការងារច្រើនម៉ោង ការប៉ះពាល់ដល់ការសិក្សារបស់ពួកគេ និងការប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ។ ចំនួន និងលទ្ធភាពនៃអ្នកធ្វើអធិការកិច្ចការងារក្នុងការដោះស្រាយបញ្ហាទាំងនេះនៅតែមានតិចតួចនៅឡើយ។ ក្របខ័ណ្ឌយ៉ាងទូលំទូលាយមួយស្តីពីរបៀបដោះស្រាយបញ្ហាពលកម្មកុមារនៅក្នុងកសិដ្ឋានដាំដុះ រួមមានយុទ្ធសាស្ត្រដែលឆ្លើយតបទៅនឹងអនុវិស័យយ៉ាងជាក់លាក់នោះ មិនទាន់មាននៅឡើយ ដែលតម្រូវឲ្យមានការរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រពីអង្គការពលកម្មអន្តរជាតិ(ILO) និងអង្គការស្បៀងអាហារនិងកសិកម្ម(FAO)។

*លក្ខខ័ណ្ឌការងារប្រកបដោយគ្រោះថ្នាក់*

ក្នុងកសិដ្ឋានទ្រង់ទ្រាយតូចទាំងផ្នែកកសិកម្ម ជលផល និងព្រៃឈើ កុមារអាចនឹងជួបប្រទះនឹងគ្រោះថ្នាក់។ អង្គការពលកម្មអន្តរជាតិបានចាត់ថ្នាក់វិស័យកសិកម្មជាវិស័យមួយដែលបរិស្ថានការងាររបស់វាងាយនឹងកើតមានគ្រោះថ្នាក់ ជាពិសេសចំពោះកុមារ។ ពួកគេច្រើនពាក់ព័ន្ធនឹងសកម្មភាពរៀបចំដី ដាំដំណាំ ប្រមូលផល និងសកម្មភាពក្រោយពេលប្រមូលផល។ យោងតាមការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ/អង្គការពលកម្មអន្តរជាតិបានឲ្យដឹងថា កុមារធ្វើការនៅក្នុងលក្ខខ័ណ្ឌការងារប្រកបដោយគ្រោះថ្នាក់នៅក្នុងវិស័យកសិកម្មប្រឈមនឹងហានិភ័យដូចខាងក្រោម៖

- ពស់ចឹក ខ្ទួយ ឬ សត្វទិច
- របួសដោយការចាប់កាន់របស់មុតស្រួច
- ពុលដោយសារការកាន់ ឬបាញ់ថ្នាំគីមីកសិកម្ម
- ត្រូវនឹងកំដៅថ្ងៃដោយគ្មានការការពារ។

ទន្ទឹមនឹងនេះ ក៏មានករណីសិក្សាមួយចំនួនស្តីពីពលកម្មកុមារនៅក្នុងវិស័យកសិកម្ម ជាពិសេស នៅក្នុងចំការដំឡូងមី និងចំការថ្នាំជក់ផងដែរ ប៉ុន្តែការអង្កេតដែលមានលក្ខណៈជាប្រព័ន្ធស្តីពីពលកម្មកុមារនៅក្នុងផ្នែកកសិកម្មជាលក្ខណៈគ្រួសារ នៅក្នុងផ្នែកព្រៃឈើ ការចិញ្ចឹមសត្វ និងពលកម្មកុមារក្នុងការងារដែលមានស្ថានភាពប្រកបដោយគ្រោះថ្នាក់ មិនទាន់បានធ្វើឡើងនៅឡើយ។

**និយមន័យនៃការងារប្រកបដោយគ្រោះថ្នាក់**

ការងារប្រកបដោយគ្រោះថ្នាក់ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ហើយត្រូវបានហាមឃាត់ដល់រូបវន្តបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ។ អនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ១៩៩៩ (លេខ១៩០) ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ បានផ្តល់នូវការបង្ហាញ ឬណែនាំនូវអ្វីជាប្រភេទនៃការងារដែលគួរត្រូវបានហាមឃាត់ដូចខាងក្រោម៖

-ការងារដែលបង្កផលប៉ះពាល់ដល់រូបរាងកាយ ផ្លូវចិត្ត ឬការរំលោភបំពានផ្លូវភេទ

-ការងារក្រោមដី ក្នុងទឹក ដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ឬនៅក្នុងលំហរតូចចង្អៀត

-ការងារប្រតិបត្តិជាមួយម៉ាស៊ីន ឧបករណ៍និងសម្ភារដែលប្រកបដោយគ្រោះថ្នាក់ ឬការងារដែលពាក់ព័ន្ធឧបករណ៍លើកដាក់ ឬដឹកជញ្ជូនបន្ទុកធ្ងន់ៗ

-ការងារនៅក្នុងបរិស្ថានដែលគ្មានផាសុខភាព ដែលអាចនឹងបង្កគ្រោះថ្នាក់ ឧទាហរណ៍នាំឲ្យកុមារជួបគ្រោះថ្នាក់ញឹកញាប់ ការងារដែលជាភ្នាក់ងារ ឬក៏ស្ថិតក្នុងដំណើរការ ឬប្រឈមនឹងសីតុណ្ហភាព កម្រិតសម្លេង ឬរំញ័រខ្លាំងដែលប៉ះពាល់ដល់សុខភាពរបស់ពួកគេ

-ការងារដែលស្ថិតនៅក្នុងស្ថានភាពលំបាកៗ ដូចជា ធ្វើការច្រើនម៉ោង ឬធ្វើការនៅពេលយប់ និង

-ការងារដែលរំខានដល់កុមារមិនអាចឲ្យពួកគេត្រលប់ទៅផ្ទះវិញបានរៀងរាល់ថ្ងៃ។

មូលហេតុចម្បងនៃពលកម្មកុមារ គឺភាពក្រីក្រ និងភាពងាយរងគ្រោះយូរអង្វែងនៅតំបន់ជនបទ។ វាជាលទ្ធផលនៃកត្តាមានឥទ្ធិពលជាអន្តរកម្មខុសៗគ្នា ដូចជាការទទួលបានគុណភាពអប់រំ និងឱកាសបណ្តុះបណ្តាលនៅមានកម្រិត ការការពារផ្នែកសង្គមនៅទន់ខ្សោយ ការយល់ដឹងនៅមានកម្រិតទាបរបស់មាតាបិតា និងសហគមន៍ ចំណាកស្រុក កង្វះការងារ និងកង្វះការងារសមរម្យសម្រាប់យុវជន។ តំបន់មួយចំនួននៃប្រទេសកម្ពុជានៅមានកង្វះការងារ ជាពិសេសតំបន់នៅជាប់ព្រំដែនប្រទេសថៃ និងវៀតណាម នាំឱ្យមានការធ្វើចំណាកស្រុកក្នុងគោលបំណងរកការងារធ្វើ ដែលទាំងនេះនាំឲ្យមានការប្រើប្រាស់ពលកម្មកុមារមកបំពេញបន្ថែមមួយចំណែកដែរ។

នៅប្រទេសកម្ពុជា កសិករក្រីក្រតែងតែពឹងផ្អែកលើការងាររបស់កុមារដើម្បីជួយបំពេញតម្រូវការភ្លាមៗក្នុងជីវភាពរបស់ពួកគេ។ ដូច្នេះ ការកាត់បន្ថយភាពក្រីក្រនៅជនបទមានការទាក់ទងយ៉ាងជិតស្និទ្ធ និងជាលក្ខខ័ណ្ឌដំបូងបង្អស់សម្រាប់ការកាត់បន្ថយពលកម្មកុមារនៅក្នុងវិស័យកសិកម្ម។ នៅពេលដែលកម្មវិធី និងគម្រោងការកសិកម្មមានទិសដៅធ្វើឱ្យកំរិតជីវភាពរបស់កសិករខ្នាតតូចមានភាពប្រសើរឡើង និងដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ កម្មវិធីនិងគម្រោងការទាំងនោះ មានតួនាទីយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយពលកម្មកុមារ ក្នុងវិស័យកសិកម្ម។ លើសពីនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចូលរួមចំណែកដល់ការការពារកុមារឱ្យនៅក្រៅពីពលកម្ម និងកាត់បន្ថយគ្រោះថ្នាក់កុមារដែលធ្វើពលកម្មនៅក្នុងវិស័យកសិកម្ម តាមរយៈការលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តាល និងលើកកម្ពស់កម្រិតជីវភាពរបស់គ្រួសារដែលងាយរងគ្រោះខ្លាំងនៅក្នុងវិស័យកសិកម្ម។

ទោះបីជាមានការអភិវឌ្ឍយ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ ស្តីពីពលកម្មកុមារក៏ដោយ ក៏នៅតែមានទម្រង់ផ្សេងៗ នៃពលកម្មកុមារជាច្រើននៅក្នុងការងារកសិកម្ម និងនេសាទជាលក្ខណៈគ្រួសារ ដែលច្បាប់ការងារបច្ចុប្បន្នមិនអាចយកទៅអនុវត្តបាន។ ដូចនេះ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតផែនការសកម្មភាពមួយដើម្បីប្រឆាំងនឹងពលកម្មកុមារ

ក្នុងការនេសាទទ្រង់ទ្រាយតូច ដែលជាឧទាហរណ៍មួយអាចឱ្យអង្គភាពផ្សេងៗទៀតនៅក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តតាម។

ក្របខ័ណ្ឌច្បាប់នេះមានសារៈសំខាន់ណាស់ ប៉ុន្តែដើម្បីដោះស្រាយបញ្ហាពលកម្មកុមារក្នុងការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាលក្ខណៈទ្រង់ទ្រាយតូច តម្រូវឲ្យមានយុទ្ធវិធីបន្ថែមទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ការយល់ដឹង និងផ្តល់ជម្រើសផ្សេងៗទៀត ដើម្បីឲ្យមានលទ្ធភាពដោះស្រាយនូវមូលហេតុដែលជាឫសគល់នៃពលកម្មកុមារទាំងនោះ។

### *ការទទួលបានការអប់រំ និងជំនាញវិជ្ជាជីវៈក្នុងវិស័យកសិកម្ម*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា កុមារគ្រប់រូប មានសិទ្ធិទទួលបានការអប់រំជាមូលដ្ឋាន។ ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ក្នុងការពង្រីកការអប់រំជាមូលដ្ឋាន ដែលមានអត្រានៃការចុះឈ្មោះចូលរៀន ៩៧% នៅក្នុងឆ្នាំ២០១៣[១៧] ប៉ុន្តែការចូលរៀនបានជាប់លាប់នៅតែជាការប្រឈមចម្បងនៅឡើយ។

ការបោះបង់ចោលសាលារៀននៅកម្រិតបឋមសិក្សាក្នុងឆ្នាំ២០១៣-២០១៤ មាន១០,៥% ដែលជាចំនួនខ្ពស់ជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍។ អត្រានៃការចុះឈ្មោះចូលរៀននៅថ្នាក់អនុវិទ្យាល័យកើនឡើងតិចតួចក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ មកត្រឹម៣៩%ក្នុងឆ្នាំ២០១៣ ដោយសារតែសិស្សលើសអាយុចូលរៀននៅកម្រិតបឋមសិក្សា កម្រិតសិស្សឡើងថ្នាក់នៅទាប (ត្រឹម៧៩%) និងកម្រិតបោះបង់ចោលការសិក្សាខ្ពស់ (២១%)។ ភាពក្រីក្រ និងការបង្រៀននៅមានកម្រិត គឺជាបញ្ហាចម្បង។ ជារួម គុណភាពនៃការអប់រំនៅតំបន់ជនបទនៅតែមានភាពខ្វះខាត។ ការវាយតម្លៃពីសមត្ថភាពអានអក្សរថ្នាក់ដំបូងនៅឆ្នាំ២០១០ ជាមួយសិស្សចំនួន២៤០០០ នាក់នៅថ្នាក់ទី១ ដល់ថ្នាក់ទី៦ បានបង្ហាញថា ៣៣ភាគរយនៃកុមារកម្ពុជាមិនអាចអានបាន ហើយ ៤៧ ភាគរយកុមារដែលចេះអក្សរ មិនអាចយល់ពីអ្វីដែលគេបានអាននោះឡើយ។ ក្រៅពីនេះមានការវាយតម្លៃផ្សេងៗទៀត បានបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំងរវាងសាលានៅជនបទ និងទីប្រជុំជន[១៨]។

កម្មវិធីស្បៀងអាហារពិភពលោក បានបង្ហាញពីទំនាក់ទំនងនៃអត្រាបោះបង់ចោលសាលារៀនខ្ពស់ទៅនឹងអសន្តិសុខស្បៀង និងភាពក្រីក្រ ដោយសារកុមារត្រូវធ្វើការដើម្បីរួមចំណែកដល់ការរកប្រាក់ចំណូលរបស់គ្រួសារ។ រីឯក្រសួងអប់រំ យុវជន និងកីឡា និងដៃគូផ្សេងទៀត បានពង្រីកការផ្តល់អាហារូបករណ៍សម្រាប់ការអប់រំជាមូលដ្ឋានដល់កុមាររស់នៅក្នុងគ្រួសារក្រីក្រ និងកំពុងបង្កើនគុណភាពនៃកាបង្រៀន តាមរយៈការពិនិត្យកម្មវិធីសិក្សាឡើងវិញ និងការកសាងសមត្ថភាព ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចូលរួមចំណែកក្នុងការលើកកម្ពស់ការអប់រំនៅតាមតំបន់ជនបទ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវសួនបន្លែ និងស្រះត្រី និងជួយដល់ការណែនាំលើជំនាញចិញ្ចឹមជីវិតដើម្បីបំពេញតម្រូវការរបស់កុមារតាមរយៈការងារកសិកម្ម ទៅក្នុងកម្មវិធីសិក្សាសម្រាប់ការអប់រំថ្នាក់បឋម និងមធ្យមសិក្សា។

ការប្រឈមផ្សេងទៀត របស់មនុស្សវ័យក្មេងនៅតំបន់ជនបទ គឺកង្វះការទទួលបាននូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាពិសេសនៅក្នុងផ្នែកកសិកម្ម។ យុវជនកម្ពុជានៅតំបន់ជនបទភាគច្រើនមាន

---

១៧. ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ទស្សនវិស័យនៃកំណែទម្រង់ការអប់រំ នៅកម្ពុជា

១៨. ធនាគារពិភពលោក (២០១៥) ការអប់រំមនុស្សជំនាន់ក្រោយ: បង្កើនគុណភាពគ្រូបង្រៀន នៅកម្ពុជា

ជំនាញទាប ហើយអត្រាអត់ការងារធ្វើមានកម្រិតខ្ពស់។ ស្ត្រី និងបុរសក្នុងផ្នែកកសិកម្មនៅតែស្ថិតក្នុងហានិភ័យដែលងាយនឹងធ្លាក់ចូលទៅក្នុងវដ្តនៃភាពក្រីក្រ[១៩]។ ពួកគេក៏ប្រឈមទៅនឹងការធ្វើចំណាកស្រុក ដើម្បីរកការងារធ្វើ ដោយគ្មានសុវត្ថិភាព ឬគ្មានជំនាញ ហើយទទួលបានការងារក្នុងផ្នែកផ្សេងៗទៀតដែលមានកម្រៃទាប។ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចូលរួមចំណែកលើកកម្ពស់ជំនាញវិជ្ជាជីវៈរបស់យុវជននៅតាមតំបន់ជនបទ ក្នុងគោលបំណងជំរុញពួកគេឱ្យក្លាយជាសហគ្រិនកសិកម្មក្នុងរយៈពេលយូរអង្វែង។

### *ការប្រែប្រួលអាកាសធាតុ និងភាពធន់ទ្រាំរបស់កុមារក្នុងវិស័យកសិកម្ម*

ការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជាគឺកើតមានពិតមែន។ ផ្អែកលើទិន្នន័យឆ្នាំ១៩៦០-២០០០ អាកាសធាតុនៅកម្ពុជាមានការប្រែប្រួលរួចទៅហើយ[២០] ហើយការប្រែប្រួលកំពស់ទឹកភ្លៀង និងសីតុណ្ហភាពនាពេលថ្មីៗនេះ នឹងរឹតតែនាំឱ្យមានការលំបាកសម្រាប់ការរស់នៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជាថែមទៀត។

បាតុភូតធម្មជាតិនាពេលថ្មីៗនេះ ដូចជាភ្លៀងធ្លាក់យឺតពេលនៅឆ្នាំ២០១០ និងការអូសបន្លាយនៃភាពរាំងស្ងួត បានបង្ហាញពីការពឹងផ្អែកទាំងស្រុងនៃសុខុមាលភាពរបស់ប្រជាជននៅជនបទ លើភាពទៀងទាត់នៃរដូវភ្លៀង ដែលជះឥទ្ធិពលដោយអាកាសធាតុ និងធនធានធម្មជាតិដែលមានស្រាប់ដូចជា ទឹកជាដើម។ ការមកដល់យឺតនៃរដូវភ្លៀងនាំឱ្យកម្រិតទឹកនៅក្នុងបឹងទន្លេសាប និងទន្លេមេគង្គមានកម្រិតទាប។

ក្នុងខែកញ្ញា ឆ្នាំ២០០៩ កសិករក្រីក្រជាច្រើនគ្រួសារនៅក្នុងខេត្តចំនួន៥ បានបាត់បង់ផលដំណាំរបស់ខ្លួនដោយសារតែព្យុះកេតសាណាដែលមិនធ្លាប់កើតមានពីមុនមក បានបំផ្លិចបំផ្លាញយ៉ាងដំណំ។[២១]

កម្មវិធីសកម្មភាពបន្សាំថ្នាក់ជាតិ (NAPA) នៃកម្ពុជា បានកំណត់តំបន់ដែលងាយរងគ្រោះខ្លាំងទៅនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ខេត្តដែលបានរកឃើញថាបានទទួលរងនូវផលប៉ះពាល់ពីទឹកជំនន់ដែលមានកម្រិតធ្ងន់ធ្ងរ និងមានវិសាលភាពធំជាងគេ គឺស្ថិតនៅក្នុងតំបន់ទំនាបនៃទន្លេសាប និងបឹងទន្លេសាប និងនៅតាមបណ្តោយទន្លេមេគង្គ។ តំបន់ទាំងនេះបានរួមចំណែកដល់ការផលិតស្រូវយ៉ាងសំខាន់ គឺជាងពាក់កណ្តាលនៃផលិតផលស្រូវសរុបទូទាំងប្រទេស។

ដោយសារតែកសិកម្មនៅប្រទេសកម្ពុជាពឹងផ្អែកលើទឹកភ្លៀងជាសំខាន់ ការប្រែប្រួលកម្ពស់ទឹកភ្លៀងនេះ នឹងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរលើលទ្ធភាពរបស់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងការទប់ទល់នឹងភាពតានតឹង និងគ្រោះភ័យនេះ។

ថ្វីបើអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយគួរឲ្យកត់សម្គាល់ក៏ដោយ ក៏គ្រួសារនៅតំបន់ជនបទភាគច្រើនគ្រាន់តែឋិតនៅលើខ្សែបន្ទាត់ក្រីក្របន្តិចបន្តួចប៉ុណ្ណោះ ហើយមួយចំនួនធំបន្តនៅក្បែរបន្ទាត់ភាពក្រីក្រនៅឡើយ។

---

១៩. អង្គការពលកម្មអន្តរជាតិ (២០១៣) ឱកាសការងារ និងការអភិវឌ្ឍជនបទ នៅកម្ពុជា៖ មធ្យោបាយដែលគោលនយោបាយការងារថ្នាក់ជាតិអាចរួមចំណែកចំពោះការសម្រេចបាននូវការងារដែលសមរម្យនៅតំបន់ជនបទ

២០. ក្រសួងបរិស្ថាន (២០១១) លទ្ធផលគន្លឹះនៃកិច្ចទំនាក់ទំនងថ្នាក់ជាតិលើកទី២ របស់កម្ពុជា ស្តីពីការប្រែប្រួលអាកាសធាតុ

២១. UNDP ក្រសួងបរិស្ថាន (២០១១) ការកសាងភាពធន់ទ្រាំ ដល់ជីវភាពរស់នៅនៅតំបន់ជនបទនៅពេលអនាគតក្នុងភាពប្រឈមនឹងការប្រែប្រួលអាកាសធាតុ របាយការណ៍ការអភិវឌ្ឍធនធានមនុស្ស នៅកម្ពុជា

ថ្វីបើមានការស្រាវជ្រាវធ្វើឡើងដើម្បីសិក្សាពីរបៀបដែលការប្រែប្រួលអាកាសធាតុជះឥទ្ធិពល ដល់ស្ត្រី និងបុរសក្នុងលក្ខណៈផ្សេងៗគ្នាក៏ដោយ ក៏នៅមានភស្តុតាងតិចតួចដែលបានរកឃើញ បញ្ជាក់ពីរបៀបដែលការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមកលើក្មេងប្រុស និងក្មេងស្រីនៅប្រទេសកម្ពុជា។ ការស្រាវជ្រាវមួយធ្វើឡើងក្នុងឆ្នាំ២០០៨[២២] បានបង្ហាញថា ភាពតានតឹងបណ្តាលមកពីការខូចខាតផលដំណាំទំនងបង្កើនបន្ទុកការងារលើកុមារ ជាពិសេសលើក្មេងស្រី តែវាហាក់ដូចជាមិនមានឥទ្ធិពលមកលើការសិក្សារបស់កុមារនៅសាលារៀននោះទេ។

ដើម្បីមានលទ្ធភាពធ្វើអន្តរាគមន៍ជាលក្ខណៈគោលនយោបាយ ក្នុងការកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងបង្កើនភាពធន់ទ្រាំរបស់កុមារ ការបង្កើនការយល់ដឹងអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើកុមារនៅក្នុងប្រទេសកម្ពុជា គឺជាតម្រូវការចាំបាច់។

## ៤.២. វិសាលភាព នៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ

តម្រូវការរបស់កុមារ និងមនុស្សវ័យក្មេងត្រូវបានកំណត់យ៉ាងច្បាស់នូវវិសាលភាពដែលមាននៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការអភិវឌ្ឍកុមារ។ ផ្អែកលើស្ថានភាពរបស់កុមារក្នុងវិស័យកសិកម្មដែលបានរៀបរាប់ខាងលើ វិស័យនៃកិច្ចអន្តរាគមន៍ចំនួនបីខាងក្រោម ដែលស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកំណត់៖

១-តម្រូវការក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីមានផ្ទៃពោះ

២-តម្រូវការក្នុងការបង្ការ និងកាត់បន្ថយពលកម្មកុមារ និងដើម្បីការពារពួកគេពីគ្រោះថ្នាក់ ដូចជាការធ្វើកសិកម្មដែលមានសារធាតុគីមី ការប្រើប្រាស់ឧបករណ៍មុតស្រួច។ល។

៣-តម្រូវការក្នុងការបង្កើនសមត្ថភាពយុវជន (អាយុ១៥-១៧) ក្នុងដំណើរការសហគ្រាសកសិកម្មប្រកបដោយផលិតភាពខ្ពស់ តាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងផ្នែកកសិកម្ម។

វិស័យនៃកិច្ចអន្តរាគមន៍ទាំងបីមានទំនាក់ទំនងជាអន្តរវិស័យ និងជាទូទៅបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាមូលហេតុចម្បងនៃពលកម្មកុមារ និងនាំឲ្យរាំងស្ទះដល់ការអភិវឌ្ឍកុមារ។ វិស័យនៃកិច្ចអន្តរាគមន៍នេះ ក៏ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគោលដៅដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៤-២០១៨) ផងដែរ។

នៅពេលដែលក្រសួងផ្សេងៗបានដឹកនាំកិច្ចអន្តរាគមន៍ទាំងនេះ (ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតសកម្មភាពរបស់ខ្លួន នៅក្នុងវិស័យអន្តរគមន៍ទាំងបីនេះ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងដៃគូពាក់ព័ន្ធផ្សេងៗ (UNICEF, FAO, WFP, USAID,...)។

ទោះបីជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីដោយឡែកក្នុងការអនុវត្តទៅតាមគោលនយោបាយកសិកម្មរបស់ខ្លួនក៏ដោយ ក៏ក្រសួងនៅតែឆ្លើយតបទៅនឹងវិស័យទាំងបីខាងលើដោយផ្ទាល់ និងទៅតាមរយៈរចនាសម្ព័ន្ធវិមជ្ឈការ និងមន្ត្រីផ្សព្វផ្សាយរបស់ខ្លួនដែលធ្វើការដោយផ្ទាល់ជាមួយនឹងកសិករ។

២២. UCW (2008) ពលកម្មកុមារ ដែលអាចបង្កគ្រោះថ្នាក់៖ ភស្តុតាងពីភូមិមួយចំនួន នៃប្រទេសកម្ពុជា

ដូចនេះ ការចូលរួម ការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាពិសេសមន្ត្រីផ្សព្វផ្សាយ គឺមានសារៈសំខាន់ណាស់ ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារ ប្រកបដោយភាពជោគជ័យ។

## ៤.៣. គោលបំណងជាយុទ្ធសាស្ត្រ និងលទ្ធផល

*គោលបំណងទី១*

**លើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភកុមារដែលងាយរងគ្រោះ តាមរយៈការបង្កើនពិពិធកម្មផលិតកម្មស្បៀង**

ដើម្បីដោះស្រាយកង្វះអាហារូបត្ថម្ភកុមារតូច ដែលមាននៅក្នុងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច (២០១៤-២០១៨) ដែលតម្រូវឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបង្កើនផលិតភាពកសិកម្ម រួមមានសួនបន្លែ ការចិញ្ចឹមសត្វ និងដំណាំចម្រុះក្នុងដីចំការ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងបង្កើតកម្មវិធី និងផែនការសកម្មភាពដើម្បីបំពេញតម្រូវការទាំងនេះ ហើយនិងជួយដល់ឪពុកម្តាយរបស់កុមារ និងអាណាព្យាបាលក្នុងការបង្កើនគ្រឿងផ្សំផ្សេងៗប្រកបដោយជីវជាតិដល់អាហាររបស់កុមារ។ កម្មវិធីនេះអាចកសាងដោយផ្អែកលើបទពិសោធន៍នៃកម្មវិធីកន្លងមក ដូចជា MALIS (FAO) និង HARVEST (USAID) រួមមានការប្រើប្រាស់ឯកសារបោះពុម្ពដែលមានស្រាប់ និងមន្ត្រីដែលបានទទួលការបណ្តុះបណ្តាលរួចហើយពីកម្មវិធីទាំងនេះ និងភ្ជាប់ទំនាក់ទំនងការងារនេះទៅនឹងការងារនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច។ កម្មវិធីនេះក៏អាចកសាងបន្ថែមផងដែរទៅលើកម្មវិធីរបស់រដ្ឋបាលជលផល ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងពាណិជ្ជកម្ម ដើម្បីបង្កើនបច្ចេកទេសក្រោយពេលប្រមូលផលត្រីតាមរយៈការជំរុញវិធីសាស្ត្រកែច្នៃ និងរក្សាទុកត្រីឲ្យបានល្អ។

លើសពីនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា នឹងគាំទ្រដល់គ្រូបង្រៀន និងសិស្សានុសិស្សក្នុងការបង្កើតសួនដំណាំក្នុងសាលា ស្រះចិញ្ចឹមត្រី និងជំនាញកសិកម្មផ្សេងៗទៀត តាមរយៈការកសាងសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេស ក៏ដូចជាការផ្តល់នូវគ្រាប់ពូជដំណាំផងដែរ។

*លទ្ធផលៈ*

១. មាតាបិតា/អាណាព្យាបាលទទួលបានព័ត៌មាននិងការកសាងសមត្ថភាពដើម្បីឲ្យការផ្តល់អាហារូបត្ថម្ភដល់កុមារដែលមានអាយុក្រោម៥ឆ្នាំមានភាពប្រសើរឡើង

២.មាតាបិតា/អាណាព្យាបាលបានអនុវត្តពិពិធកម្មផលិតកម្មស្បៀង តាមរយៈសួនដំណាំ និងការចិញ្ចឹមសត្វតាមផ្ទះ

៣. គ្រូបង្រៀន និងកុមារបានយល់ដឹងអំពីសារៈសំខាន់នៃអាហារូបត្ថម្ភតាមរយៈការធ្វើសួនដំណាំក្នុងសាលារៀន។

*គោលបំណងទី២*

**បង្ការ និងទប់ស្កាត់កុមារពីពលកម្មកុមារ និងការងារប្រកបដោយគ្រោះថ្នាក់ក្នុងវិស័យកសិកម្ម**

កុមារជាច្រើននៅក្នុងគ្រួសារដែលពឹងផ្អែកលើកសិកម្ម ព្រៃឈើ និងនេសាទ មានកាតព្វកិច្ចជួយឪពុកម្តាយរបស់ខ្លួនក្នុងការបង្កើនប្រាក់ចំណូលគ្រួសារ ដែលវាចាំបាច់ណាស់ក្នុងការលុបបំបាត់ភាពក្រីក្រដែលជាមូលហេតុ ឬសគល់នៃពលកម្មកុមារ។ នេះគឺជាការងារស្នូលមួយសម្រាប់គ្រប់អង្គភាពទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អនុលោមទៅតាមអនុក្រិត្យ ស្តីពីការការពារកុមារ និងក្រមសីលធម៌ការពារកុមារដែលបង្កើតឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៣៨ និង១៨២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងយកចិត្តទុកដាក់កាន់តែល្អិតល្អន់ថែមទៀតអំពីក្រុមសុវត្ថិភាពសម្រាប់ការពារកុមារ និងទប់ស្កាត់កុមារពីការងារប្រកបដោយគ្រោះថ្នាក់ក្នុងវិស័យកសិកម្ម។

ក្រសួងនឹងធានាថា រាល់កម្មវិធី និងគម្រោងរបស់ខ្លួន ក៏ដូចជារបស់អង្គការដៃគូនានាដែលកំពុងធ្វើការក្នុងវិស័យកសិកម្ម នឹងជះឥទ្ធិពលជាវិជ្ជមានទៅលើស្ថានភាពការងាររបស់កុមារ។ ឥទ្ធិពលដែលអាចកើតមានទៅលើកុមារតាមរយៈគម្រោងកសិកម្មនានា នឹងត្រូវបានវាយតម្លៃក្នុងនីតិវិធីនៃការធ្វើផែនការ ការតាមដាន និងការវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គម្រោង និងកម្មវិធីនឹងត្រូវបានបង្កើតឡើងក្នុងល័ក្ខខ័ណ្ឌមួយដែលមិនធ្វើឲ្យប៉ះពាល់ដល់ពលកម្មកុមារនោះឡើយ។ ក្នុងករណីដែល កុមារទាំងនេះកំពុងជួយឪពុកម្តាយរបស់ពួកគេក្នុងការងារប្រចាំថ្ងៃក្នុងគ្រួសារ ក្រសួងនឹងធានាថាការងារទាំងនោះ គឺជាការងារដែលកុមាររីករាយនឹងធ្វើ ហើយដែលមិនប៉ះពាល់ដល់ការសិក្សារបស់ពួកគេនៅសាលារៀន និងជាការងារដែលមិនបង្កឲ្យមានគ្រោះថ្នាក់ ហើយកុមារដែលមានអាយុត្រឹម១២ ទៅ១៥ឆ្នាំ អាចធ្វើតែការងារដែលស្រាលៗប៉ុណ្ណោះ។

លើសពីនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអនុវត្តន៍នូវវិធានការជាក់លាក់ដើម្បីបង្ការកុមារពីហានិភ័យ និងពលកម្មកុមារ តាមរយៈការបង្កើនការយល់ដឹងដល់ឪពុកម្តាយអំពីផលប៉ះពាល់ជាអវិជ្ជមាននៃពលកម្មកុមារដល់កូនៗរបស់ពួកគេ ហើយនឹងជួយឪពុកម្តាយដោយផ្តល់នូវជម្រើសផ្សេងៗទៀត ក្រៅពីស្ថានភាពការងារប្រកបដោយគ្រោះថ្នាក់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតយន្តការដើម្បីធ្វើការដោះស្រាយជាមួយនឹងអ្នកជំនួញដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ដោយធានាថារាល់ការប្រតិបត្តិនៃអ្នកពាក់ព័ន្ធទាំងនោះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំស្តីពីការការពារកុមាររបស់ក្រសួង។

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតរួចទៅហើយនូវផែនការសកម្មភាពស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យជលផល។ ស្រដៀងគ្នានេះ អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ នាយកដ្ឋានកសិ-ឧស្សាហកម្ម នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និងរដ្ឋបាលព្រៃឈើ គួរបង្កើតផែនការសកម្មភាពនេះផងដែរ។

បច្ចុប្បន្ននេះ នៅតែមានកង្វះខាតព័ត៌មានស្តីពីស្ថានភាពកុមារនៅក្នុងផ្នែកបសុសត្វ និងព្រៃឈើ។ ដើម្បីដោះស្រាយបញ្ហាពលកម្មកុមារនៅក្នុងផ្នែកទាំងនេះ ជំហានដំបូងគួរតែប្រមូលព័ត៌មានបន្ថែមអំពីស្ថាន

ភាពការងារ និងការរស់នៅរបស់កុមារ។ ព័ត៌មានអាចប្រមូលបានតាមរយៈការធ្វើការអង្កេត ឬប៉ាន់ប្រមាណយ៉ាងរហ័សមួយ។

*លទ្ធផលៈ*

១. ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យកសិកម្មត្រូវបានលុបបំបាត់

២. ពលកម្មកុមារក្នុងវិស័យកសិកម្មត្រូវបានកាត់បន្ថយ ស្របទៅនឹងគោលដៅជាតិនៃការកាត់បន្ថយពលកម្មកុមារ។

*គោលបំណងទី៣*

**បង្កើនជំនាញវិជ្ជាជីវៈដល់យុវជន និងលើកកម្ពស់ការចូលរួមរបស់ពួកគេក្នុងផលិតកម្មកសិកម្ម**

ដើម្បីមានលទ្ធភាពផ្តល់ដល់មនុស្សវ័យក្មេង (អាយុ ១៥ទៅ១៧ ឆ្នាំ) នូវអនាគតល្អក្នុងវិស័យកសិកម្ម ពួកគេត្រូវតែឆ្លងកាត់ការបណ្តុះបណ្តាលដើម្បីឲ្យក្លាយជាកសិករមានជំនាញ ដែលនឹងអាចដំណើរការសហគ្រាសកសិកម្មប្រកបដោយជោគជ័យ។ ការបណ្តុះបណ្តាលនេះត្រូវតែឆ្លើយតបទៅនឹងយេនឌ័រ ដោយយកចិត្តទុកដាក់ទៅលើលទ្ធភាព និងបញ្ហាប្រឈមផ្សេងៗគ្នាទៅលើក្មេងស្រី និងក្មេងប្រុស។ លើសពីនេះទៅទៀតជាសមាជិកនៃគ្រួសារក្រីក្រ យុវជន (អាយុ១៥-១៧ឆ្នាំ) ជាពិសេសអ្នកដែលបោះបង់ចោលការសិក្សាគួរត្រូវបានផ្តល់ឲ្យនូវការបណ្តុះបណ្តាល និងការគាំទ្រផ្នែកធនធាន/ធាតុចូល សម្រាប់ជីវភាពដែលពឹងផ្អែកលើរបរកសិកម្ម និងមិនមែនកសិកម្ម ហើយនិងប្រភពប្រាក់ចំណូលផ្សេងៗ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបទពិសោធន៍យូរអង្វែងក្នុងការធ្វើការងារជាមួយសាលាស្រែកសិករ រួមមានបណ្តាញទូលំទូលាយនៃគ្រូបង្គោល (សម្របសម្រួលដោយកម្មវិធីជាតិគ្រប់គ្រងសត្វចង្រៃ នៃអគ្គនាយកដ្ឋានកសិកម្ម)។ បទពិសោធន៍នេះអាចប្រើប្រាស់ដើម្បីបង្កើតសាលាស្រែកសិករគំរូមួយដែលបំពេញតម្រូវការយុវជនលើជំនាញ និងបទពិសោធន៍ការងារចិញ្ចឹមជីវិត ជាពិសេសការយល់ដឹងពីសេដ្ឋកិច្ច និងយន្តការខ្សែសង្វាក់តម្លៃ។

ដើម្បីឲ្យការបណ្តុះបណ្តាលឆ្លើយតបទៅនឹងតម្រូវការយុវជន វាសំខាន់ណាស់ដែលមនុស្សវ័យក្មេងត្រូវបានផ្តល់លទ្ធភាពឲ្យចូលរួមក្នុងការរៀបចំវគ្គបណ្តុះបណ្តាលទាំងនោះ។

*លទ្ធផលៈ*

១. មនុស្សវ័យក្មេង (អាយុចាប់ពី ១៥ទៅ ១៧ឆ្នាំ) ត្រូវបានផ្តល់នូវជំនាញ និងចំណេះដឹងចាំបាច់ដើម្បីប្រែក្លាយពួកគេទៅជាកសិករ និងសហគ្រិនកសិកម្ម ដែលប្រកបទៅដោយជំនាញច្បាស់លាស់។

២. មនុស្សវ័យក្មេង (អាយុ ១៥ ទៅ ១៧ឆ្នាំ) បានយល់ដឹងអំពីទំនាក់ទំនងរវាងកសិកម្ម និងការប្រែប្រួលអាកាសធាតុ ការត្រៀមបម្រុងនិងការឆ្លើយតបនឹងគ្រោះមហន្តរាយ។

*គោលបំណងទី៤*

**ពង្រឹងសមត្ថភាពស្ថាប័ន ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការធានាបាននូវការបញ្ជ្រាបការអភិវឌ្ឍ និងសុវត្ថិភាពកុមារ ក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព**

ដើម្បីមានលទ្ធភាពអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្រ្ត និងបង្កើតផែនការសកម្មភាពដែលអាចឆ្លើយតបបាន បុគ្គលិករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែយល់ដឹង និងបណ្តុះបណ្តាលទៅលើការអភិវឌ្ឍកុមារភាព និងការបង្ការកុមារពីពលកម្មកុមារ។ បុគ្គលិករបស់ក្រសួងត្រូវតែយល់ដឹងពីគ្រោះថ្នាក់ដែលអាចកើតមាន និងជះឥទ្ធិពលដល់កុមារក្នុងការងារកសិកម្ម និងត្រូវតែមានលទ្ធភាពផ្តល់នូវជម្រើសផ្សេងៗទៀតដែលមិនជះឥទ្ធិពលអាក្រក់ដល់កុមារ។ ដោយវាជាបញ្ហាអន្តរវិស័យ ក្នុងនោះក៏មានតម្រូវការជាក់លាក់មួយទៀត គឺការបង្កើនការយល់ដឹង និងបណ្តុះបណ្តាលមន្រ្តីផ្សព្វផ្សាយដោយសារតែពួកគេធ្វើការដោយផ្ទាល់ជាមួយនឹងសហគមន៍ និងកសិករ។

លើសពីនេះក៏មានតម្រូវការមួយទៀតផងដែរ ក្នុងការកសាងសមត្ថភាព និងសមត្ថកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការវាយតម្លៃ និងការបញ្ជ្រាបការអភិវឌ្ឍ និងការការពារកុមារទៅក្នុងគោលនយោបាយកសិកម្ម កម្មវិធី និងគម្រោងនានា ក៏ដូចជាក្នុងការអនុវត្តជាប្រចាំរបស់អនុវិស័យនីមួយៗ។

ការបញ្ជ្រាបការអភិវឌ្ឍ និងការការពារកុមារ និងយេនឌ័រ គួរត្រូវរៀបចំឡើងតំណាលគ្នា ឬជាមួយគ្នា ដើម្បីអាចបង្កើតបាននូវកម្លាំងរួមមួយ និងអាចកាត់បន្ថយតម្រូវការពេលវេលា និងតម្លៃ។

*លទ្ធផលៈ*

១. ការអភិវឌ្ឍនិងការការពារកុមារ ត្រូវបានបញ្ជ្រាបចូលនៅគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. សមាជិកនៃគណៈគម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនាញ និងធនធានគ្រប់គ្រាន់ដើម្បីបំពេញការងាររបស់ខ្លួនលើការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង ការរៀបចំផែនការ និងការកសាងភាពជាដៃគូសម្រាប់កុមារក្នុងវិស័យកសិកម្ម

៣. ថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ដឹង និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្ត ស្តីពីការអភិវឌ្ឍ និងការការពារកុមារ។

## ៤.៤. យុទ្ធសាស្រ្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងកំណត់យកអភិក្រមសំខាន់ៗចំនួន២ ដើម្បីសម្រេចបាននូវការអភិវឌ្ឍ និងការការពារកុមារ។

ទី១: ក្រសួងនឹងកសាងសមត្ថភាពផ្ទៃក្នុងរបស់ខ្លួនដើម្បីបញ្ជ្រាបការអភិវឌ្ឍ និងការការពារកុមារឲ្យមានប្រសិទ្ធភាពនៅគ្រប់កម្មវិធី និងគម្រោងទាំងអស់ ហើយនិងបង្កើតក្រុមឃ្លាំមើលបញ្ហា ឬការងារនេះ។

ទី២: ក្រសួងនឹងរៀបចំបង្កើតកម្មវិធីដោះស្រាយបញ្ហាបន្ទាន់បំផុតមួយចំនួន ដែលកុមារងាយរងគ្រោះនៅតំបន់ជនបទជួបប្រទះ ដូចដែលបានរៀបរាប់ក្នុងចំណុចខាងដើម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងធ្វើការជាដៃគូជាមួយនឹងក្រសួងពាក់ព័ន្ធផ្សេងៗទៀត ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនានា។

ជំហានជាយុទ្ធសាស្ត្រខាងក្រោមនេះ គឺមានសារៈសំខាន់សម្រាប់ការអនុវត្តគោលនយោបាយ និង ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារប្រកបដោយប្រសិទ្ធភាព៖

១. **ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងការកសាងសមត្ថភាពក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ៖** មូលដ្ឋានសម្រាប់ការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និង ការពារកុមារក្នុងវិស័យកសិកម្ម គឺជាការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពចាំបាច់មួយ ចំនួននៅក្នុងក្រសួង។ បុគ្គលិកទាំងអស់ត្រូវតែយល់ដឹងអំពីភាពពាក់ព័ន្ធនៃការអភិវឌ្ឍនិងការការពារ កុមារនៅក្នុងការងាររបស់ពួកគេប្រចាំថ្ងៃ។ លើសពីនេះទៅទៀត គណៈកម្មាធិការសម្របសម្រួល បច្ចេកទេសកុមារតូចនឹងត្រូវរៀបចំយុទ្ធសាស្ត្រយ៉ាងច្បាស់លាស់ ដើម្បីផ្សព្វផ្សាយពីសារ សំខាន់ៗ នៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនឹងរៀបចំយ៉ាងល្អិតល្អន់ (រួមគ្នាជាមួយនឹងក្រសួង និងអង្គការដៃគូដែលពាក់ព័ន្ធ) នូវផែនការ កសាងសមត្ថភាពនេះ។ ដោយមន្ត្រីផ្សព្វផ្សាយ ការិយាល័យកសិកម្មស្រុក និងមន្ទីរកសិកម្មខេត្តត្រូវ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តកម្មវិធី និងគម្រោងលើកកម្ពស់ការអភិវឌ្ឍ និងការការពារកុមារ នេះ ហើយពួកគេនឹងបញ្ចូលការអភិវឌ្ឍនិងការពារកុមារទៅក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ ដូចនេះ ចាំបាច់ក្រសួងគប្បីយកចិត្តទុកដាក់ជាពិសេស លើការកសាងសមត្ថភាពដល់ពួកគេ។

២. **ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងជាមួយកសិករ ឪពុកម្តាយ អង្គការ និងសហគមន៍កសិកម្ម និង វិស័យឯកជន ស្តីពីសារៈសំខាន់នៃការអភិវឌ្ឍកុមារ និងផលប៉ះពាល់ជាអវិជ្ជមាននៃពលកម្មកុមារ ដល់កូនៗរបស់ពួកគេ៖** ពលកម្មកុមារក្នុងផ្នែកកសិកម្ម ច្រើនកើតមានឡើងក្នុងគ្រួសារក្រីក្រទីទ័ល ដែលពួកគេមានភាពតានតឹងខ្លាំងរួចទៅហើយ ដូចនេះ កិច្ចទំនាក់ទំនងត្រូវតែព្យាយាមធ្វើយ៉ាងណា មិនបង្កើនសំពាធដល់ពួកគេថែមទៀត។ ទាំងនេះ គឺត្រូវការនូវយុទ្ធសាស្ត្រទំនាក់ទំនងមួយដែលផ្អែកលើ ការនិយាយពន្យល់ និងការផ្តល់ជម្រើស និងដំណោះស្រាយផ្សេងៗ និងកាត់បន្ថយការស្តីបន្ទោស ដល់ពួកគេ។ គួរបង្កើតផងដែរនូវឯកសារ សម្ភារនិងគោលការណ៍ណែនាំនានា ដោយពឹងផ្អែកលើ ឯកសារដែលមានស្រាប់របស់អង្គការដៃគូ ដូចជា អង្គការស្បៀងនិងកសិកម្ម និងអង្គការពលកម្មអន្តរជាតិ។

៣. **ការកសាងសម្ព័ន្ធភាព និងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង និងអង្គការដៃគូដែលពាក់ព័ន្ធ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចូលរួមយ៉ាងសកម្មក្នុងយន្តការសម្របសម្រួលកិច្ច គាំពារ និងអភិវឌ្ឍន៍កុមាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ ឧទាហរណ៍ ដូចជា ក្រុមប្រឹក្សា ជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច។ ការងារនេះនឹង សម្របសម្រួលដល់ការបង្កើតកម្លាំងរួមដើម្បីកំណត់នូវការអនុវត្តដ៏ល្អបំផុតមួយ ក៏ដូចជាដើម្បីចែក រំលែកព័ត៌មាន និងចំណេះដឹងនានា។

៤. **ការបង្កើតគម្រោង និងកម្មវិធីស្របទៅនឹងវិស័យទាំងបីនៃកិច្ចអន្តរាគមន៍៖** ជាមួយនឹងក្រសួង និង អង្គការដៃគូនានា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំបង្កើតនូវគម្រោង និងកម្មវិធី ជាក់លាក់នានា សម្រាប់វិស័យទាំងបីនៃកិច្ចអន្តរាគមន៍ដែលបានកំណត់នៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ។ ដើម្បីជៀសវាង «ភាពច្រំដែលនៃអន្តរាគមន៍» ជំហានដំបូងនឹងត្រូវធ្វើ គឺការរៀបចំផែនទីយ៉ាងទំលំទូលាយមួយ ដើម្បីពិនិត្យមើលកម្មវិធី និងគម្រោង ឯកសារ និងការបោះ ពុម្ពផ្សាយផ្សេងៗដែលមានស្រាប់ និងវាយតម្លៃថាតើអភិក្រម និងការងារមួយណាដែលសមស្រប បំផុតសម្រាប់បរិបទកម្ពុជា។

៥. **លើកកម្ពស់ការចូលរួមរបស់កុមារ និងយុវជនក្នុងការរៀបចំបង្កើត និងអនុវត្តន៍គោលនយោបាយ គម្រោង និងកម្មវិធីផ្សេងៗ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងស្វែងរកលទ្ធភាពដើម្បីធ្វើសហប្រតិបត្តិការជាមួយនឹងអង្គការកុមារនិង/ឬយុវជននៅក្នុងតំបន់ជនបទដែលមានស្រាប់ក្នុងគោលបំណង រៀបចំគម្រោង ឬបង្កើតយន្តការផ្សេងៗទៀតដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារ និងយុវជនទាំងនោះ។

## ៨.៥. ការអនុវត្ត

ទំនួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារ គឺស្ថិតលើថ្នាក់កំពូលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអ្នកសម្រេចផ្តល់ការឯកភាពលើគោលនយោបាយនេះ។

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច គឺជាអង្គភាពដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងដឹកនាំការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គណៈកម្មាធិការនេះ ទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយនឹងក្រសួង ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ក៏ដូចជាជម្រុញការប្រឹក្សាលើគោលនយោបាយអភិវឌ្ឍន៍ និងការពារកុមារនេះ។ លើសពីនេះទៅទៀត គណៈកម្មាធិការនឹងទទួលខុសត្រូវលើការដឹកនាំ និងបង្កើតផែនការសកម្មភាពដែលរួមទាំងផែនការសម្រាប់ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលផងដែរ។គណៈកម្មាធិការនេះក៏ នឹងទទួលខុសត្រូវក្នុងការសម្របសម្រួលបញ្ជ្រាបការអភិវឌ្ឍ និងការការពារកុមារ នៅតាមអង្គភាពក្រោមឱវាទក្រសួងទាំងអស់។

គណៈកម្មាធិការនឹងរាយការណ៍ជូនរដ្ឋមន្ត្រីពីលទ្ធផលការងាររបស់ខ្លួនជាប្រចាំឆ្នាំ។ តួនាទីនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច[២៣] គឺធានានូវប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការការពារកុមារក្នុងវិស័យកសិកម្ម។ គណៈកម្មាធិការក៏ទទួលបន្ទុកផងដែរ លើការសម្របសម្រួលការអនុវត្ត ការតាមដាន និងការវាយតម្លៃគម្រោង និងសកម្មភាព នៅពេលដែលអង្គភាពពាក់ព័ន្ធផ្សេងៗ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវលើការអនុវត្ត។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច អង្គភាពពាក់ព័ន្ធទាំងអស់របស់ក្រសួង ត្រូវទទួលបន្ទុកក្នុងការបង្កើតផែនការការងារ សម្រាប់យកទៅអនុវត្តកិច្ចការពារ និងអភិវឌ្ឍន៍កុមារទៅតាមវិស័យរបស់ពួកគេ។ ការដាក់បញ្ចូលនូវការអភិវឌ្ឍ និងការការពារកុមារទៅក្នុងផែនការ និងក្របខ័ណ្ឌនៃការតាមដាន និងវាយតម្លៃដែលមានស្រាប់ គឺជាការទទួលខុសត្រូវរបស់នាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈ កម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច។

---

២៣.ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

## ៨.៦. ធនធានហិរញ្ញវត្ថុ

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ បានបង្ហាញពីវិស័យនៃការធ្វើអន្តរាគមន៍។ ទាំងនេះនឹងត្រូវបានបញ្ជាក់យ៉ាងច្បាស់ថែមទៀតនៅក្នុងដំណាក់កាលនៃការធ្វើផែនការលំអិតជាបន្តបន្ទាប់។ ការកំណត់តម្លៃ និងពេលវេលានឹងត្រូវបានបញ្ចូលទៅក្នុងការធ្វើផែនការផងដែរ។ សកម្មភាពដែលបានលើកឡើងជាច្រើននៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ នឹងត្រូវធ្វើឲ្យប្រសើរឡើងក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងពាក់ព័ន្ធ និងយន្តការសម្របសម្រួលផ្សេងទៀត (ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច) និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលនានា។ កញ្ចប់ថវិកាដែលត្រូវការ អាស្រ័យលើវិសាលភាព និងទំហំនៃសកម្មភាពដែលបានកំណត់នៅក្នុងផែនការសកម្មភាព។

សម្រាប់ការអនុវត្តប្រកបដោយភាពជោគជ័យ ក៏ដូចជាការសម្រេចបានយ៉ាងពេញលេញនូវទិសដៅ និងគោលបំណងដែលបានកំណត់នៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ក៏ដូចជាធនធានផ្សេងៗទៀត ពីប្រភពផ្សេងៗគ្នា រួមមាន រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន -ល- គឺជាតម្រូវការចាំបាច់។

## ៨.៧. ការតាមដាន និងការវាយតម្លៃ

ការតាមដាន និងការវាយតម្លៃនឹងត្រូវធ្វើឡើងតាមវិធី២យ៉ាង ៖

១. កម្មវិធី និងគម្រោងកសិកម្មមានទំនាក់ទំនងដោយផ្ទាល់ និងដោយមិនផ្ទាល់ទៅលើការអភិវឌ្ឍកុមារភាពនិងពលកម្មកុមារ ថ្វីត្បិតតែកម្មវិធី និងគម្រោងទាំងនោះមិនបានដោះស្រាយបញ្ហានេះដោយផ្ទាល់ក៏ដោយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការវាស់វែងឥទ្ធិពលគម្រោង សំណុំសូចនាករដែលមានលក្ខណៈស្តង់ដាមួយគួរត្រូវបានបង្កើត និងដាក់បញ្ចូលទៅក្នុងនីតិវិធីតាមដាន និងវាយតម្លៃដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដោយយោងទៅលើគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រព័ន្ធតាមដាន និងវាយតម្លៃភាពឆ្លើយតបយេនឌ័រ គឺជាតម្រូវការចាំបាច់។ ការរៀបចំប្រព័ន្ធតាមដាន និងវាយតំលៃនេះគួរតែពិចារណាអំពីភាពឆ្លើយតបយេនឌ័រនិងកុមារផងដែរ។ ឯកសារណែនាំដែលមានស្រាប់របស់អង្គការស្បៀងអាហារ និងកសិកម្ម ស្តីពីការតាមដាន និងវាយតម្លៃពលកម្មកុមារក្នុងវិស័យកសិកម្ម គួរតែត្រូវបានយកជាលំនាំសម្រាប់ប្រព័ន្ធតាមដាន និងវាយតម្លៃនេះ។ ឯកសារនេះ គួរត្រូវបានយកមកប្រើប្រាស់ក្នុងនីតិវិធីនៃការធ្វើផែនការ ការតាមដាន និងការវាយតម្លៃដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។

២.ការតាមដានការអនុវត្តគោលយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពារកុមារនេះនឹងត្រូវបានធ្វើឡើង តាមរយៈការប្រជុំជាប្រចាំរវាងសមាជិកនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច ជាមួយនឹងជនបង្គោលថ្នាក់ខេត្ត ក៏ដូចជាតាមរយៈការពិនិត្យមើលឡើងវិញនូវសកម្មភាពនិងលទ្ធផលដែលសម្រេចបានប្រចាំឆ្នាំ។ លទ្ធផល ការរីកចំរើន និងឧបសគ្គនៃការអនុវត្តទាំងនោះ នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

## ៥. ផែនការសកម្មភាព

| លទ្ធផល | សកម្មភាពជាអាទិភាព | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | រយៈពេលអនុវត្ត | អង្គភាពទទួលខុសត្រូវ | ដៃគូសហការ |
|---|---|---|---|---|---|---|
| **គោលបំណងទី១៖ លើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភកុមារដែលងាយរងគ្រោះ តាមរយៈការបង្កើនពិពិធកម្មផលិតកម្មស្បៀង។**<br>សូចនាករនៃលទ្ធផល៖ ភាពក្រិនក្នុងចំណោមកុមារដែលមានអាយុក្រោម៥ឆ្នាំ ត្រូវបានថយចុះក្នុងបណ្តាខេត្ត ត្រឹម ១០%នៅឆ្នាំ២០២០ (ការអង្កេតសុខភាព និងអត្រានុកូលសាស្ត្រកម្ពុជា) | | | | | | |
| មាតាបិតា/អាណាព្យាបាលទទួលបានព័ត៌មាន និងការកសាងសមត្ថភាពដើម្បីឲ្យការផ្តល់អាហារូបត្ថម្ភដល់កុមារដែលមានអាយុក្រោម៥ឆ្នាំមានភាពប្រសើរឡើង | រៀបចំវគ្គផ្សព្វផ្សាយស្តីពីកុមារ និងអាហារូបត្ថម្ភសម្រាប់សហគមន៍ | -ចំនួនវគ្គផ្សព្វផ្សាយដែលបានរៀបចំ<br>-អ្នកចូលរួម៥០នាក់ /វគ្គ ៥ខេត្ត/ឆ្នាំ (សរុប២៥វគ្គ) | -របាយការណ៍វគ្គផ្សព្វផ្សាយ<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៦-២០២០ | គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច (TCCECCD)<br>មន្ទីរកសិកម្មខេត្ត | FAO, (EU), World Food Program, UNICEF, USAID, Plan International, Save the Children, MoRD, MoWA, MoYES, MoH |
| | កសាងសមត្ថភាពមាតាបិតា/អាណាព្យាបាល នៅតំបន់អនុវត្តន៍គម្រោងស្តីពីកុមារ និងអាហារូបត្ថម្ភ | ចំនួនមាតាបិតា/អាណាព្យាបាលដែលបានបណ្តុះបណ្តាល | -របាយការណ៍វគ្គបណ្តុះបណ្តាល<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៦-២០២០ | TCCECCD<br>មន្ទីរកសិកម្មខេត្ត | FAO, (EU), World Food Program, UNICEF, USAID, Plan International, Save the Children, MoRD, MoWA, MoYES, MoH |

| | | | | | | |
|---|---|---|---|---|---|---|
| | ជំរុញនិងធ្វើឲ្យមាននិរន្តភាពនូវការផ្លាស់ប្តូរឥរិយាបទទាក់ទងនឹងការអនុវត្តរបបអាហារ និងអាហារូបត្ថម្ភកុមារ តាមរយៈទូរទស្សន៍និងវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ | -ចំនួនកម្មវិធីទូរទស្សន៍ និងវិទ្យុ ឬស្ព័តដែលបានរៀបចំនិងចាក់ផ្សាយ | -កាលវិភាគចាក់ផ្សាយ | ២០១៦-២០២០ | TCCECCD | MoH, MoYES, MoInformation, Development Partners, Save the Children |
| មាតាបិតា/អាណាព្យាបាលបានអនុវត្តន៍ពិពិធកម្មផលិតកម្មស្បៀង តាមរយៈសួនដំណាំ និងការចិញ្ចឹមសត្វតាមផ្ទះ | រៀបចំវគ្គបណ្តុះបណ្តាលទៅកាន់មន្ត្រីផ្សព្វផ្សាយស្តីពីអាហារូបត្ថម្ភចម្រុះក្នុងប្រព័ន្ធផលិតកម្មស្បៀងចម្រុះតាមផ្ទះ (ដំណាំ ការចិញ្ចឹមសត្វ និងការកែច្នៃចំណីអាហារខ្នាតតូច) ដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ | -ចំនួនមន្ត្រីផ្សព្វផ្សាយដែលបានបណ្តុះបណ្តាល<br>-៣០នាក់/វគ្គ ៥ខេត្ត/ឆ្នាំ<br>-ចំនួនប្រជាជនឬអាណាព្យាបាលដែលបានបណ្តុះបណ្តាល | -របាយការណ៍វគ្គបណ្តុះបណ្តាល<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៦ | TCCECCD | FAO, USAID, (EU), WHO IFAD/SPIRE, MoRD |
| | បណ្តុះបណ្តាលមាតាបិតា និងអាណាព្យាបាលស្តីពីការប្រើប្រាស់សួនដំណាំតាមផ្ទះ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ | -%នៃមាតាបិតា/អាណាព្យាបាលដែលបានបណ្តុះបណ្តាលបានប្រើប្រាស់បច្ចេកទេសដើម្បីលើកកម្ពស់អាហារូបត្ថម្ភកុមារ | ការធ្វើតេស្តមុន និងក្រោយវគ្គ | ២០១៦-២០២០ | មន្ទីរកសិកម្មខេត្ត | FAO, USAID, EU, WHO IFAD/ASPIRE, MoRD, Save the Children |
| | ផ្តល់គ្រាប់ពូជដំណាំ កូនត្រី ពូជសត្វ និងមធ្យោបាយចាំបាច់ដទៃទៀតដល់មាតាបិតា/អាណាព្យាបាលក្នុងតំបន់អនុវត្តន៍គម្រោង | -%នៃមាតាបិតា/អាណាព្យាបាលដែលបានទទួលជំនួយឧបត្ថម្ភនេះ បានបង្កើនអាហារូបត្ថម្ភកុមារ<br>-គោលដៅ ៨០% | ការធ្វើតេស្តមុន និងក្រោយពេលអនុវត្តន៍គម្រោង | ២០១៦-២០២០ | មន្ទីរកសិកម្មខេត្ត | FAO, USAID, EU, WHO IFAD/ASPIRE, MoRD |
| គ្រូបង្រៀន និងកុមារបានយល់ដឹងអំពីសារៈសំខាន់នៃអាហារូបត្ថម្ភតាមរយៈការធ្វើសួនដំណាំក្នុងសាលារៀន | សម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការបង្កើតកម្មវិធីសួនដំណាំសាកល្បងក្នុងសាលារៀន | ផែនការសកម្មភាពដែលបានព្រមព្រៀងគ្នាជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡាសម្រាប់កម្មវិធីសួនដំណាំសាកល្បង | ផែនការ | ២០១៦-២០១៧ | TCCECCD ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) | World Food Program, Plan International , USAID, FAO, UNICEF |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំឯកសារបង្រៀនសម្រាប់ការសាកល្បង (ដែលអាចប្រើប្រាស់នៅពេលបន្ទាប់សម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូថ្នាក់បឋមសិក្សា) | ឯកសារបង្រៀន | ច្បាប់ចម្លងឯកសារបង្រៀន | ២០១៧ | TCCECCD MoEYS | World Food Program, Plan International , USAID, FAO, UNICEF |
| | បណ្តុះបណ្តាលគ្រូពីការថែទាំសួនដំណាំក្នុងសាលារៀន | សាលារៀនចំនួន១០ | -របាយការណ៍វគ្គបណ្តុះបណ្តាល<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៧-២០១៨ | TCCECCD MoEYS | World Food Program, Plan International , USAID, FAO, UNICEF |
| | ជម្រុញសាលារៀនគោលដៅក្នុងការបង្កើតសួនដំណាំក្នុងសាលារៀន | -ចំនួនសួនដំណាំក្នុងសាលារៀន ដែលបានបង្កើត<br>-គោលដៅចំនួន១០ សួន | របាយការណ៍ពីសាលារៀននីមួយៗ | ២០១៧-២០១៩ | TCCECCD MoEYS | World Food Program, Plan International , USAID, FAO, UNICEF |

| គោលបំណងទី២៖ បង្ការ និងទប់ស្កាត់កុមារពីពលកម្មកុមារ និងការងារប្រកបដោយគ្រោះថ្នាក់ ក្នុងវិស័យកសិកម្ម<br>សូចនាករនៃលទ្ធផល៖<br>- អាត្រាពលកម្មកុមារដែលប្រកបដោយគ្រោះថ្នាក់ (ការអង្កេតពលកម្មកុមារ)<br>- ចំនួនករណីដែលបានរាយការណ៍ពីកុមាររងគ្រោះដោយថ្នាំពុលកសិកម្មត្រូវបានថយចុះ<br>- អាត្រាពលកម្មកុមារក្នុងអនុវិស័យ (ការអង្កេតស្តីពីពលកម្មកុមារ) | | | | | | |
|---|---|---|---|---|---|---|
| ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យកសិកម្មត្រូវបានលុបបំបាត់ | កំណត់នូវអ្វីដែលជាគ្រោះថ្នាក់ចំពោះកុមារ និងកុមារដែលធ្វើការងារក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ក្នុងអនុវិស័យនីមួយៗ ដោយគិតទៅលើភាពខុសគ្នានៃយេនឌ័រ (ការសិក្សាវាយតម្លៃរហ័ស) | បញ្ជីរៀបរាប់ពីគ្រោះថ្នាក់និងការងារប្រកបដោយគ្រោះថ្នាក់ចំពោះកុមារក្នុងអនុវិស័យនីមួយៗត្រូវបានបង្កើត | បញ្ជីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវិស័យនីមួយៗ | ២០១៦-១៧ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | កំណត់ប្រភេទការងារដែលគ្រោះថ្នាក់ចំពោះកុមារនៅក្នុងអនុវិស័យនីមួយៗ | បញ្ជីប្រភេទការងារគ្រោះថ្នាក់ចំពោះកុមារនៅក្នុងអនុវិស័យនីមួយៗ | ច្បាប់ចម្លងបញ្ជីប្រភេទការងារគ្រោះថ្នាក់ចំពោះកុមារ | ២០១៧-១៨ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | បង្កើតសេចក្តីណែនាំស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារតាមអនុវិស័យនីមួយៗ | សេចក្តីណែនាំស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារតាមអនុវិស័យនីមួយៗ | ច្បាប់ចម្លងសេចក្តីណែនាំ | ២០១៧-១៨ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | កសាងសមត្ថភាពមន្រ្តីផ្សព្វផ្សាយស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | -ចំនួនមន្ត្រីផ្សព្វផ្សាយដែលបានបណ្តុះបណ្តាល<br>-៣០០នាក់ | របាយការណ៍វគ្គបណ្តុះបណ្តាល បញ្ជីឈ្មោះចូលរួម | ២០១៦-២០ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការងារប្រកបដោយគ្រោះថ្នាក់ចំពោះកុមារទៅកាន់ក្រុមគោលដៅ | -ចំនួនវគ្គផ្សព្វផ្សាយដែលបានរៀបចំ<br>-២០០ វគ្គ | របាយការណ៍វគ្គផ្សព្វផ្សាយ | ២០១៧-២០ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |

| | | | | | | |
|---|---|---|---|---|---|---|
| ពលកម្មកុមារក្នុងវិស័យកសិកម្ម ត្រូវបានកាត់បន្ថយ ស្របទៅនឹងគោលដៅជាតិ នៃការកាត់បន្ថយពលកម្មកុមារ | ធ្វើអង្កេត/វាយតម្លៃទៅលើស្ថានភាពកុមារតាមអនុវិស័យនីមួយៗ | ចំនួនការអង្កេតដែលបានធ្វើ គោលដៅចំនួន៤ គឺកសិកម្ម ជលផល ព្រៃឈើ និងកៅស៊ូ | ច្បាប់ចម្លងរបាយការណ៍ | ២០១៦-១៨ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | បង្កើតសេចក្តីណែនាំស្តីពីការប្រឆាំងនឹងពលកម្មកុមារតាមអនុវិស័យ | សេចក្តីណែនាំស្តីពីការប្រឆាំងនឹងពលកម្មកុមារតាមអនុវិស័យផ្សេងៗគ្នា នៃក្រសួង ត្រូវបានចេញឲ្យប្រើប្រាស់ | ច្បាប់ចម្លងសេចក្តីណែនាំ | ២០១៧-១៨ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | បណ្តុះបណ្តាលគ្រូបង្គោលលើសេចក្តីណែនាំនានា | -ចំនួនគ្រូបង្គោលដែលបានទទួលការបណ្តុះបណ្តាល (វគ្គបណ្តុះបណ្តាលលើកដំបូង និងវគ្គរំលឹកឡើងវិញ)<br>-គោលដៅចំនួន៣០នាក់ | របាយការណ៍វគ្គបណ្តុះបណ្តាល | ២០១៨-១៩ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | បណ្តុះបណ្តាលជនបង្គោល មន្ត្រីផ្សព្វផ្សាយ និងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើសេចក្តីណែនាំនានា | -ចំនួនបុគ្គលិកដែលបានបណ្តុះបណ្តាល<br>-៤០០នាក់ | -របាយការណ៍វគ្គបណ្តុះបណ្តាល<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៨-២០ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | រៀបចំវគ្គផ្សព្វផ្សាយសម្រាប់កសិករពីផលប៉ះពាល់នៃពលកម្មកុមារក្នុងការធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងវិធីកាត់បន្ថយពលកម្មកុមារទាំងនោះ | -ចំនួនវគ្គផ្សព្វផ្សាយដែលបានរៀបចំ<br>-គោលដៅចំនួន២០០វគ្គ | របាយការណ៍ | ២០១៨-២០ | រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | ILO, FAO, World Vision, MoLVT |
| | បង្កើតអភិក្រមរួមគ្នាមួយរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម ស្តីពីពលកម្មកុមារនៅក្នុងកសិដ្ឋានដាំដុះ | សេចក្តីថ្លែងការណ៍រួមគ្នា | ច្បាប់ចម្លងសេចក្តីថ្លែងការណ៍រួម | ២០១៦ | TCCECCD | MoLVT, MoC |

| គោលបំណងទី៣. បង្កើនជំនាញវិជ្ជាជីវៈដល់យុវជន និងលើកកម្ពស់ការចូលរួមរបស់ពួកគេក្នុងផលិតកម្មកសិកម្ម<br>សូចនាករនៃលទ្ធផល៖ ចំនួនមនុស្សវ័យក្មេងដែលបានក្លាយជាកសិករ និងសហគ្រិនកសិកម្មប្រកបដោយជំនាញច្បាស់លាស់ | | | | | | |
|---|---|---|---|---|---|---|
| មនុស្សវ័យក្មេង (អាយុចាប់ពី ១៥ទៅ ១៧ឆ្នាំ) ត្រូវបានផ្តល់នូវជំនាញ និងចំណេះដឹងចាំបាច់ ដើម្បីប្រែក្លាយពួកគេទៅជាកសិករ និងសហគ្រិនកសិកម្ម ដែលប្រកបទៅដោយជំនាញច្បាស់លាស់ | រៀបចំការវាយតម្លៃពីតម្រូវការនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់មនុស្សវ័យក្មេង (១៥-១៧ឆ្នាំ) | ការវាយតម្លៃពីតម្រូវការនៃការបណ្តុះបណ្តាលត្រូវបានធ្វើឡើង | របាយការណ៍នៃការវាយតម្លៃ | ២០១៦ | TCCECCD / ក្រុមការងារយេនឌ័រ និងកុមារ (GCWG) | FAO, EU, ILO, SDP-SDC |
| | បង្កើតសាលារៀនស្រែកសិករស្របទៅនឹងតម្រូវការយុវជនរួមមានការផ្តល់ថវិកា/សម្ភារ និងការទទួលបានប្រព័ន្ធព័ត៌មានទីផ្សារ | សាលារៀនស្រែកសិករគម្រូត្រូវបានបង្កើតសម្រាប់យុវជន | កម្មវិធី/សម្ភារៈបណ្តុះបណ្តាល | ២០១៧ | TCCECCD / GCWG រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ | FAO, ILO, EU, World Vision, private sector |
| | បង្កើតកម្មវិធីបណ្តុះបណ្តាលនៅក្នុងតំបន់អនុវត្តន៍គម្រោងសាកល្បងចំនួន ២កន្លែង | ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាល | របាយការណ៍វគ្គបណ្តុះបណ្តាល | ២០១៧ | TCCECCD / GCWG | FAO, ILO, EU, World Vision, private sector |
| | បង្កើតកម្មវិធីសន្សំដើម្បីការផ្លាស់ប្តូរសម្រាប់យុវជន | -ចំនួនយុវជនដែលចូលរួមក្នុងកម្មវិធីសន្សំដើម្បីការផ្លាស់ប្តូរ ២៤<br>-គោលដៅ ១៥០០ នាក់ | របាយការណ៍របស់ OXFAM MIS | ២០១៦-២០ | OXFAM TCCECCD / GCWG | Local partners,, OXFAM |

| | | | | | | |
|---|---|---|---|---|---|---|
| | ពង្រឹងសមត្ថភាពយុវជនដែលបានបោះបង់ការសិក្សាអំពីសហគ្រាសខ្នាតតូច | -ចំនួនយុវជនដែលបានទទួលការបណ្តុះបណ្តាល<br>-%នៃសិក្ខាកាមដែលបានរាយការណ៍ពីជំនួញរបស់គេកំពុងដំណើរការ<br>-គោលដៅ ៣៥០នាក់<br>-សិក្ខាកាម២៥% បានរាយការណ៍ពីជំនួញរបស់គេកំពុងដំណើរការ | របាយការណ៍របស់ OXFAM MIS | ២០១៦-១៩ | OXFAM | Local partners, OXFAM, TCCECCD / GCWG |
| មនុស្សវ័យក្មេង (អាយុ ១៥ ទៅ ១៧ឆ្នាំ) បានយល់ដឹងអំពីទំនាក់ទំនងរវាងកសិកម្ម និងការប្រែប្រួលអាកាសធាតុ ការត្រៀមបម្រុងនិងការឆ្លើយតបនឹងគ្រោះមហន្តរាយ | បង្កើតឯកសារបង្រៀនសម្រាប់មនុស្សវ័យក្មេងស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម | ឯកសារមេរៀនដែលបានបង្កើត | ច្បាប់ចម្លងឯកសារបង្រៀនដែលបានបោះពុម្ព | ២០១៦ | TCCECCD / GCWG | ADB-SNV, UNDP, World Bank, Plan International, UNEP |
| | រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មនុស្សវ័យក្មេងស្តីពីកសិកម្ម និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | ចំនួនមនុស្សវ័យក្មេងដែលបានទទួលការបណ្តុះបណ្តាល | របាយការណ៍វគ្គបណ្តុះបណ្តាល | ២០១៧-១៩ | TCCECCD / GCWG | ADB-SNV, UNDP, World Bank, Plan International |
| | រៀបចំវេទិកាយុវជនស្តីពីកសិកម្ម ការចិញ្ចឹមជីវិត ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ល។ | វេទិកាយុវជនត្រូវបានបង្កើតឡើង | របាយការណ៍វេទិកា | ២០១៧-២០ | TCCECCD / GCWG | FAO,ILO, UNDP, OXFAM, ADB, UNICEF, World Vision |

| គោលបំណងទី៤៖ ពង្រឹងសមត្ថភាពស្ថាប័ន ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការធានាបាននូវការបញ្ជ្រាបការអភិវឌ្ឍ និងសុវត្ថិភាពកុមារក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព<br>សូចនាករ នៃលទ្ធផល៖<br>- តម្រូវការនៃការអភិវឌ្ឍ និងការការពារកុមារ គឺត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ យុទ្ធសាស្រ្ត និងកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ផែនការយុទ្ធសាស្រ្តថវិកា)<br>- ចំនួនគម្រោង/កម្មវិធីរួមគ្នា និងកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងក្រសួងពាក់ព័ន្ធ (កិច្ចព្រមព្រៀង) | | | | | | |
|---|---|---|---|---|---|---|
| ការអភិវឌ្ឍ និងការការពារកុមារ ត្រូវបានបញ្ជ្រាបចូលនៅគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ផ្សព្វផ្សាយគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | -ចំនួនវគ្គផ្សព្វផ្សាយ ៣វគ្គ/ឆ្នាំ (ថ្នាក់ជាតិ១វគ្គ និងខេត្ត២វគ្គ)<br>-អ្នកចូលរួមសរុប ១៥០នាក់/ឆ្នាំ | -របាយការណ៍វគ្គផ្សព្វផ្សាយ<br>-បញ្ជីឈ្មោះអ្នកចូលរួម | ២០១៦-១៧ | TCCECCD / GCWG | EU, FAO, Save the Children |
| | បង្កើតផែនការសកម្មភាពលម្អិតតាមរដ្ឋបាលនីមួយៗ នាយកដ្ឋានពាក់ព័ន្ធ មន្ទីរកសិកម្មខេត្ត ។ល។ ស្តីពីការបញ្ជ្រាបការអភិវឌ្ឍ និងការពារកុមារ | -ផែនការសកម្មភាព ជាមួយនឹងកញ្ចប់ថវិកា<br>-គោលដៅ៖ គ្រប់រដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ មន្ទីរកសិកម្មខេត្ត | ផែនការសកម្មភាព និងថវិកា | ២០១៧ | រដ្ឋបាល, នាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរកសិកម្មខេត្ត | TCCECCD / GCWG<br>EU, FAO, ILO<br>Spanish (Spain International Sort) |
| | តាមដានការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍន៍ និងការពារកុមារ | របាយការណ៍រៀងរាល់ ៦ខែម្តង | របាយការណ៍ | ២០១៦-២០ | TCCECCD / GCWG | Administrations Line Departments and PDA |
| សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនាញ និងធនធានគ្រប់គ្រាន់ដើម្បីបំពេញ | រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំ សម្រាប់ថ្នាក់ដឹកនាំក្រសួង និងដៃគូអភិវឌ្ឍន៍ស្តីពីការបញ្ជ្រាបគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងការពារកុមារ | សិក្ខាសាលាប្រចាំឆ្នាំត្រូវបានរៀបចំ (សរុប៥សិក្ខាសាលា) | របាយការណ៍សិក្ខាសាលា | ២០១៦-២០ | TCCECCD / GCWG | ILO, FAO, World Vision, UNICEF, UNDP, EU |

| | | | | | | |
|---|---|---|---|---|---|---|
| ការងាររបស់ខ្លួន លើការតស៊ូមតិ ការលើកកម្ពស់ការយល់ដឹង ការរៀបចំផែនការ និងការកសាងភាពជាដៃគូ សម្រាប់កុមារក្នុងវិស័យកសិកម្ម | កសាងសមត្ថភាព និងជំនាញបច្ចេកទេសស្តីពីកុមារ ក្នុងវិស័យកសិកម្មក្នុងចំណោមសមាជិក គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចនៃក្រសួងកសិកម្ម និងជនបង្គោលថ្នាក់ខេត្ត | ២ វគ្គ /ឆ្នាំ | របាយការណ៍វគ្គបណ្តុះបណ្តាល | . ២០១៦-២០ | TCCECCD | FAO, ILO, Save the Children, Oxfam, Plan International |
| | កសាងសមត្ថភាពស្តីពីការគ្រប់គ្រងគម្រោង ការតស៊ូមតិ និងភាពជាអ្នកដឹកនាំដល់សមាជិកគណៈគម្មាធិការសម្របសម្រួលបច្ចេកទេស កុមារតូចនៃក្រសួងកសិកម្ម និងជនបង្គោលថ្នាក់ខេត្ត | -១ វគ្គថ្នាក់ជាតិ<br>-២ វគ្គ ថ្នាក់ខេត្ត | របាយការណ៍វគ្គបណ្តុះបណ្តាល | ២០១៦-១៧ | TCCECCD | FAO, ILO, Save the Children, Oxfam, Plan International |
| | រៀបចំទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសកម្ពុជាស្តីពីការអភិវឌ្ឍ និងការពារកុមារ ក្នុងវិស័យកសិកម្ម | -២ ដង ក្នុងប្រទេស /ឆ្នាំ<br>-១ដង ក្រៅប្រទេស/ឆ្នាំ | របាយការណ៍ | ២០១៧-២០ | TCCECCD | FAO, ILO, Save the Children, Oxfam, Plan International |
| ថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ដឹង និងអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍ និងការពារកុមារ | ផ្សព្វផ្សាយគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ និង ទៅកាន់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សិក្ខាសាលាផ្សព្វផ្សាយត្រូវបានរៀបចំឡើង | របាយការណ៍សិក្ខាសាលា | ២០១៦ | TCCECCD | FAO, ILO, EU, |

| | | | | | | |
|---|---|---|---|---|---|---|
| | ធ្វើសហប្រតិបត្តិការ ជាមួយនឹងអង្គការពលកម្មអន្តរជាតិទៅលើការបង្កើនចំណេះដឹងស្តីពីពលកម្មកុមារ ដោយផ្តល់នូវវគ្គបណ្តុះបណ្តាល | -១ វគ្គថ្នាក់ជាតិ (៣០នាក់)<br>-២ វគ្គថ្នាក់ខេត្ត (៦០នាក់) | របាយការណ៍វគ្គបណ្តុះបណ្តាល | ២០១៧ | TCCECCD | ILO |
| | ដាក់បញ្ចូលគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងឯកសារពាក់ព័ន្ធដទៃទៀត នៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | គោលនយោបាយ និងព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការពារកុមារមាននៅក្នុងគេហទំព័ររបស់ក្រសួង | ច្បាប់ចម្លងអត្ថបទពីក្នុងគេហទំព័រ | ២០១៦-២០ | TCCECCD | |
| | បញ្ចូលការអភិវឌ្ឍកុមារ និងយេនឌ័រ ទៅក្នុងកម្មវិធីសាលាជាតិកសិកម្ម | ការអភិវឌ្ឍ និងការពារកុមារ និងបញ្ហាយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាកសិកម្ម | កម្មវិធីសិក្សារបស់សាលាជាតិកសិកម្ម | ២០១៨-២០ | TCCECCD | FAO could collaborate with others |

២៤.ភាពធន់ទ្រាំ និងការដាក់បញ្ចូលហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្របំផុត: ប្រជាជនក្រីក្របំផុតមិនមានគណនីធនាគារមួយជាផ្លូវការ។ ជាមួយនឹងថវិកាបន្តិចបន្តួចក្នុងការសន្សំ ពួកគេ និងគ្រួសាររបស់គេ គឺងាយនឹងទទួលរងគ្រោះចំពោះភាពទ័លក្រនៃជីវភាព។ សហគមន៍ផ្អែកលើក្រុមសន្សំ ដោយការសន្សំសម្រាប់ការផ្លាស់ប្តូរ គឺត្រូវបានផ្តួចផ្តើមឡើងដើម្បីផ្តល់នូវយន្តការសម្រាប់ភាពរឹងមាំនៃជីវភាពរបស់ពួកគេ។